**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្ដីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Sep-2019, 11:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហ្វួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS (Reserve)

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# មាតិកា

I. និដ្ឋភាពរួម ........................................................ 1

II. ភាពអាចទទួលយកបាន ................................................ 4

III. អង្គសេចក្តី ........................................................ 11

ក. ការឆ្លើយតបចំពោះការអះអាងរបស់ សប្រកាន់ចោទលែងលើកដីកាសម្រេចនៃភាពស្ថានអំពី .អ.ព. ...11

ខ ការអះអាងរបស់ចំពោះតបឆ្លើយការ .ស.អ.ព. អំពីផលវិបាកនៃដីកាដំណោះស្រាយផ្ទុយគ្នា .........13

១ពេលឡើយ នៅជម្រះជំនុំកាលដំណាក់ទៅបន្តត្រូវរឿងក្តីថា ចែងបានមិន .ក.ត.វ.ក្របខណ្ឌ អ . ក្នុងចេញបានជម្រះ ត្រូវជំនុំទៅរឿងបញ្ជូនដីកា ប្រកាន់ និងចោទលែងលើកដីកាសម្រេចមានដែល ពេលដំណាលគ្នានោះ ........................................................ 13

២. គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* កំណត់ថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ................................ 32

IV. សន្និដ្ឋាន ........................................................ 43

## I. និជ្ឈភាពរួម

១. ទោះជាអះអាងថាបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនអាចទទួលយកបាន ដោយសារតែគាត់មិនបានជំទាស់នឹងការសម្រេចផ្នែកអង្គហេតុ ការសន្និដ្ឋានផ្លូវច្បាប់ ឬ ការសម្រេចលើយុត្តាធិការបុគ្គល ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ[1] ក៏សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") នៅតែអូសទាញអង្គបុរេជំនុំជម្រះ ("អ.ប.ជ.") ឱ្យពិចារណាលើការជំទាស់យុត្តាធិការ ដែលលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត[2] ដោយបញ្ចុះបញ្ចូល អ.ប.ជ. ឱ្យតាក់តែងឡើងវិញ នូវកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង វិធានផ្ទៃក្នុង ដោយមិនអើពើនឹងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* និង អនុវត្ត "គោលនយោបាយសម្រេចសេចក្តី" ដែលមិនមានរូបរាង ពោលគឺ *នៅពេលដែលសហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") ពីរនាក់ ដែលមានឋានៈស្មើគ្នា ចេញដីកាដំណោះស្រាយផ្ទុយគ្នាស្រឡះ ដែលមានកម្លាំងអនុវត្តដូចគ្នា រឿងក្តីត្រូវបន្តទៅជំនុំជម្រះនៅក្នុងសវនាការ*។

២. ដោយអះអាងថា វិធាន ៧៧(១៣)(ខ) គឺជា *ច្បាប់ពិសេស* ដូច្នេះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវមានអានុភាពជាស្វ័យប្រវត្តិលើដីកាសម្រេចលើកលែងចោទប្រកាន់នោះ[3] ស.ព.អ. បាននាំឱ្យ អ.ប.ជ. មិនត្រឹមតែរំលោភបំពានទៅលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ប៉ុណ្ណោះទេ ថែមទាំងដាក់ឱ្យសហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ.") យូ ប៊ុនឡេង មានឋានៈទាបជាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") Michael Bohlander ដោយដកហូតពី ស.ច.ស.ជ. នូវឋានៈ និង អំណាចឆន្ទានុសិទ្ធិស្មើគ្នាជាមួយ ស.ច.ស.អ. ក្នុងការបង្ហាញការរកឃើញ និង ការសន្និដ្ឋានរបស់គាត់ នៅក្នុងដីកាដំណោះស្រាយរបស់គាត់ផ្ទាល់[4]។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D267) ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D267/10 ("ចម្លើយតបរបស់ ស.ព.អ.") កថាខណ្ឌ ២, កថាខណ្ឌ ៧។

[2] កថាខណ្ឌ ៦ នៃចម្លើយតបរបស់ ស.ព.អ.។

[3] កថាខណ្ឌ ២៥ នៃចម្លើយតបរបស់ ស.ព.អ.។

[4] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត") កថាខណ្ឌ ៤១, កថាខណ្ឌ ៤៥-៤៦។

៣. ដោយអះអាងថា វិធាន ៧៧(១៣)(ខ) "បង្ហាញអំពីចេតនាក្នុងការអនុវត្តអាណត្តិយ៉ាងច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក. និង ច្បាប់ អ.វ.ត.ក."[5] ស.ព.អ. ជម្រុញ អ.ប.ជ. ឱ្យចាត់ទុកដីកាដំណោះស្រាយផ្ទុយគ្នា ថាជាករណីខ្វែងយោបល់គ្នាដែលមិនមានដំណោះស្រាយ ដោយបញ្ចូលគ្នានូវយន្តការដោះស្រាយវិវាទ សម្រាប់ដំណាក់កាលស៊ើបអង្កេត នៃកិច្ចដំណើរការនីតិវិធីមុនជំនុំជម្រះជាមួយនីតិវិធីបណ្តឹងឧទ្ធរណ៍ ហើយកំណត់លក្ខណៈខុសចំពោះក្របខណ្ឌ អ.វ.ត.ក. ប្រវត្តិចរចា និង យុត្តិសាស្ត្រ។ នៅក្នុងជើងទំព័រដែលពិបាករកមើល (needle-in-the-haystack) ស.ព.អ. បានទទួលស្គាល់ថា ឯកសារគាំទ្ររបស់គាត់ "ទាក់ទងនឹងយន្តការដោះស្រាយវិវាទផ្លូវការ... មិនបញ្ជាក់ពីស្ថានភាពច្បាស់លាស់ នៅក្នុងករណីបច្ចុប្បន្ននេះទេ"[6]។

៤. ដោយអះអាងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ *តែងតែ* មានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ លើកលែងតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលប់នោះ ស.ព.អ. បាននាំ អ.ប.ជ. ឱ្យយល់ខុស ក្នុងការពិចារណាថា មិនមានវិមតិសង្ស័យដែលត្រូវដោះស្រាយ តាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ឡើយ ដោយសារតែគោលការណ៍នេះ មិនអនុវត្តចំពោះស្ថានភាពនីតិវិធីដែលមានភាពមិនច្បាស់លាស់[7]។ ក្រៅតែពីថា មិនមានភាពមិនច្បាស់លាស់ផ្នែកនីតិវិធី ឬ *ចន្លោះប្រហោង* ស.ព.អ. បង្ហាញថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* មិនអនុវត្តចំពោះការដោះស្រាយវិមតិសង្ស័យ ពាក់ព័ន្ធនឹងអង្គហេតុ និង ការបកស្រាយបទប្បញ្ញត្តិច្បាប់ នៅដំណាក់កាលមុនជំនុំជម្រះ[8] ដោយព្យាយាមនាំ អ.ប.ជ. ទៅរកផ្លូវខុស ដោយមិនអើពើនឹង *វិមតិសង្ស័យ* ដែលមិនអាចជំទាស់បាន កើតចេញពីការសម្រេចផ្នែកអង្គហេតុដែលផ្ទុយគ្នា និង ការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. គឺជា *វិមតិសង្ស័យ* ដែលចាំបាច់ត្រូវដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត តាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*[9]។

---

[5] កថាខណ្ឌ ២៥ នៃចម្លើយតបរបស់ ស.ព.អ.។

[6] កថាខណ្ឌ ២៦ ជើងទំព័រ ៩២ នៃចម្លើយតបរបស់ ស.ព.អ.។

[7] កថាខណ្ឌ ៤០-៤១ នៃចម្លើយតបរបស់ ស.ព.អ.។

[8] កថាខណ្ឌ ៣៨, កថាខណ្ឌ ៤១-៤៣ នៃចម្លើយតបរបស់ ស.ព.អ.។

[9] *សូមមើល* កថាខណ្ឌ ១៣-៣១, កថាខណ្ឌ ៤៩-៦៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

៥. ដោយអះអាងថា "ដំណោះស្រាយសមហេតុផលបំផុត"[10] ដើម្បីដោះស្រាយដីកាដំណោះស្រាយផ្ទុយគ្នា គឺត្រូវបញ្ជូនលោក មាស មុត ទៅជំនុំជម្រះនៅក្នុងសវនាការ *ដែលនៅដំណាក់កាលនោះ* គាត់អាចប្រើប្រាស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់គាត់ ជាពិសេសសិទ្ធិទទួលបានសច្ចាធារណ៍និរទោស និង ផលវិបាកនានារបស់សច្ចធាណ៍នោះ គឺគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ស.ព.អ. ជម្រុញ អ.ប.ជ. ឱ្យអនុម័តយកដំណោះស្រាយមួយដែលមិនសមហេតុផល និង អយុត្តិធម៌។ ការដែលថាលោក មាស មុត ជាបុរសវ័យចំណាស់អាយុ ៨១ ឆ្នាំ[11] គួរឆ្លងកាត់ដំណើរការជំនុំជម្រះដែលលេបត្របាក់ជីវិត (life-sucking)[12] ដើម្បីទទួលបានសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញ និង "ផលប្រយោជន៍" ពីការសម្រេចដោយសំឡេងភាគច្រើនលើសលប់របស់អង្គជំនុំជម្រះសាលាដំបូង[13] ដើម្បីគ្រាន់តែទទួលបានការលើកលែងការចោទប្រកាន់ ដោយសារតែវិមតិសង្ស័យមានអត្ថិភាពរួចទៅហើយ ចំពោះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. លើរូបគាត់នោះ និង ថា បទដ្ឋានបង្ហាញភស្តុតាងនៅសវនាការ គឺខ្ពស់ជាងបទដ្ឋានសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[14] គឺជារឿងគួរឱ្យស្អប់ខ្ពើម។

៦. ដីកាសម្រេចលើកលែងចោទប្រកាន់ មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ប្រសិនបើ អ.ប.ជ. មិនបានសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ (ដែលក្នុងករណី

---

[10] កថាខណ្ឌ ៣៨ នៃចម្លើយតបរបស់ ស.ព.អ.។

[11] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174 EN 01187674។

[12] ប្រវត្តិនៃសំណុំរឿងរបស់ អ.វ.ត.ក. បានបង្ហាញថា ការឃុំខ្លួន និង សវនាការដែលពន្យាលពេល ទៅលើជនជាប់ចោទវ័យចំណាស់បានសម្លាប់ពួកគាត់បន្តិចម្តងៗ។ *សូមមើល រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ ឯកសារ E270/1។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៥ ឯកសារ E359/1។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ នួន ជា ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៩ ឯកសារ F46/3។

[13] កថាខណ្ឌ ៣៨ នៃចម្លើយតបរបស់ ស.ព.អ.។

[14] *សូមមើល* វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៣២៣។

នេះ គឺគ្មាន)[15] រឿងក្តីប្រឆាំងលោក មាស មុត ត្រូវតែច្រានចោល។ ហើយបើទោះបីជា អ.ប.ជ. អាចច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់បានក៏ដោយ ក៏ អ.ប.ជ. ត្រូវសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលប់នោះដែរ ដើម្បីឱ្យរឿងក្តីប្រឆាំងលោក មាស មុត អាចបន្តទៅដំណាក់កាលជំនុំជម្រះបាន[16]។

## II. ភាពអាចទទួលយកបាន

៧. ***បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត អាចទទួលយកបានតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ទោះបីជាបកស្រាយដោយឡែក ឬ រួមគ្នាជាមួយវិធាន ២១*** ស.ព.អ. អះអាងដោយឡោលៗថា បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនអាចទទួលយកបានឡើយ តាមវិធាន ៧៤(៣)(ក) និង វិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារតែបណ្តឹងឧទ្ធរណ៍នេះ មិនបានលើកឡើងអំពីកំហុសឆ្គង ឬ ការរំលោភបំពានលើឆន្ទានុសិទ្ធិ ទាក់ទងនឹងការសម្រេចផ្នែកអង្គហេតុ ការសន្និដ្ឋានផ្លូវច្បាប់ ឬការសម្រេចពីយុត្តាធិការបុគ្គលរបស់ ស.ច.ស.អ.[17] ប៉ុន្តែបែរជាគាំទ្រដោយប្រយោលចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ ដោយស្នើសុំឱ្យ អ.ប.ជ. ដោះស្រាយបញ្ហាយុត្តាធិការដែលលោក មាស មុត បានលើកឡើង ពោលគឺថា តើដីកាដំណោះស្រាយមួយណាក្នុងចំណោមដីកាដំណោះស្រាយទាំងពីរដែលផ្ទុយគ្នារបស់ ស.ច.ស. គួរតម្កល់ទុកជាបានការនោះ[18]។

៨. ស.ព.អ. ចាប់បញ្ចូលគ្នានូវបទដ្ឋានត្រួតពិនិត្យរបស់ អ.ប.ជ. ជាមួយភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍[19]។ បទដ្ឋានត្រួតពិនិត្យទាក់ទងនឹងថា តើបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត នឹងទទួលជោគជ័យលើអង្គសេចក្តីដែរឬយ៉ាងណា[20]។ ភាពអាចទទួលយកបានទាក់ទងនឹងថាតើ អ.ប.ជ.

---

[15] *សូមមើល* កថាខណ្ឌ ១៣-៣១, កថាខណ្ឌ ៥២-៦៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ ចម្លើយរបស់មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D266/5 ("ចម្លើយតបរបស់ មាស មុត") កថាខណ្ឌ ២១-៩៨។

[16] *សូមមើល* កថាខណ្ឌ ៤៦, កថាខណ្ឌ ៦៤, កថាខណ្ឌ ៧០ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ២០, កថាខណ្ឌ ៩៨ នៃចម្លើយតបរបស់ មាស មុត។

[17] កថាខណ្ឌ ២, កថាខណ្ឌ ៧-៨ នៃចម្លើយតបរបស់ ស.ព.អ.។

[18] កថាខណ្ឌ ៦ នៃចម្លើយតបរបស់ ស.ព.អ.។

[19] កថាខណ្ឌ ៧ នៃចម្លើយតបរបស់ ស.ព.អ.។

[20] អ.ប.ជ. នឹងបដិសេធចោលសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិរបស់ ស.ច.ស. តែក្នុងករណីដែលសេចក្តីសម្រេចនោះ៖ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (គឺកំហុសអង្គច្បាប់) ដែលនាំឱ្យសេចក្តីសម្រេចនោះ គ្មានសុពលភាព

អាចពិចារណាបានដែរឬយ៉ាងណា ទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ ដូចជាថាតើបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត ស្របជាមួយការជំទាស់ចំពោះដីការបស់ ស.ច.ស. ដែលមានចែងតាមវិធាន ៧៤(៣) ឬយ៉ាងណា[21]។ ដើម្បីប្រយោជន៍សេដ្ឋកិច្ចតុលាការ លោក មាស មុត មិនបានជំទាស់ចំពោះការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស.អ. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់នោះទេ ដោយសារតែចំណុចនេះពាក់ព័ន្ធនឹងបញ្ហាចម្រុះ ទាំងអង្គហេតុ និង អង្គច្បាប់[22] គឺជាការសម្រេច "ដែលត្រូវធ្វើឡើងនៅពេលសវនាការ ផ្អែកតាមការសួរដេញដោល និង ការវិនិច្ឆ័យលើភស្តុតាងដែលពាក់ព័ន្ធ"[23]។ ជំនួសវិញ លោក មាស មុត បានរក្សាសិទ្ធិក្នុងការជំទាស់ការសម្រេចផ្អែកអង្គហេតុ និង ការសន្និដ្ឋានលើអង្គច្បាប់នៅក្នុងសវនាការវិញ ប្រសិនបើរឿងក្តីនេះត្រូវបន្ត[24]។

៩. ស.ព.អ. យល់ខុសចំពោះវិធាន ៧៤(៣)(ក)។ ខណៈដែលអះអាងថា បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនមែនជាបណ្តឹងឧទ្ធរណ៍ ជំទាស់ដីកាសម្រេចបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក.

---

(២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត (គឺកំហុសអង្គហេតុ) ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬ មិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេត មានកំហុសធ្ងន់ ឬការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន"។ *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[21] *សូមមើល រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ១៨៖ "អនុលោមតាមវិធាន ៧៤(៣) ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាឬសេចក្តីសម្រេច ចំនួនប្រាំបួនប្រភេទ ដែលសម្រេចដោយ ក.ស.ច.ស."។

[22] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជតក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៣៧។

[23] *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៦។

[24] កថាខណ្ឌ ១១ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

ព្រោះ "មិនមែនជាបណ្តឹងឧទ្ធរណ៍ *ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*"[25] ស.ព.អ. បែរជាយល់ស្របថា វិធាន ៧៤(៣)(ក) គ្របដណ្តប់ទៅលើបណ្តឹងឧទ្ធរណ៍ ជំទាស់ដីកាសម្រេចបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក. លើ "បុគ្គល ពេលវេលា និង រឿងក្តី"[26]។ ស.ច.ស.អ. បានបញ្ជាក់ពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ទៅលើលោក មាស មុត នៅពេលដែលគាត់បកស្រាយដោយខុសឆ្គងទៅលើវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដោយគាត់បានលើកឡើងថា បើ អ.ប.ជ. មិនតម្កល់ដីកាដំណោះស្រាយណាមួយ ដោយសំឡេងភាគច្រើនលើសលប់ទេនោះ ដីកាដំណោះស្រាយទាំងពីរ ឬមានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ប៉ុណ្ណោះ ដែលត្រូវមានអានុភាពអនុវត្ត[27]។

១០. ស.ព.អ. អះអាងដោយនាំឱ្យយល់ខុសថា ដើម្បីឱ្យបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត អាចទទួលយកបាន តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង លោក មាស មុត គួរតែបានស្នើដល់ អ.ប.ជ. ឱ្យច្រានចោល ឬ កែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ[28]។ ប៉ុន្តែទាំងវិធានផ្ទៃក្នុង និង យុត្តិសាស្ត្ររបស់ អ.វ.ត.ក. មិនបានតម្រូវបែបនេះឡើយ។ លោក មាស មុត គ្រាន់តែត្រូវស្នើសុំដំណោះស្រាយដែលមិនមានលក្ខណៈជាការទាយស្មានប៉ុណ្ណោះ[29]។ ការស្នើសុំឱ្យលើកលែងចោទប្រកាន់ មិនមែនជាការទាយស្មាននោះទេ[30]។

[25] កថាខណ្ឌ ៧ នៃចម្លើយតបរបស់ ស.ព.អ. (ការគូសបញ្ជាក់ក្នុងឯកសារដើម)។

[26] កថាខណ្ឌ ៧ នៃចម្លើយតបរបស់ ស.ព.អ. ដែលដកស្រង់ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៧។

[27] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ ១៩ ជើងទំព័រ ២៦ ដែលដកស្រង់ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៦។ កថាខណ្ឌ ៥៧៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[28] កថាខណ្ឌ ៧ នៃចម្លើយតបរបស់ ស.ព.អ.។

[29] *សូមមើល រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៥៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ៣១ (សម្រេចថា អ.ប.ជ. "នឹងមិនពិចារណាពាក់ព័ន្ធនឹងបញ្ហាថា តើម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំប្រភេទជាក់លាក់មួយនៃការជួសជុលសំណងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះឡើយ")។

[30] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទំព័រ ៤៦។

១១. ស.ព.អ. អះអាងដោយមិនត្រឹមត្រូវថា បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនអាចទទួលយកបាន ដោយសារតែបណ្តឹងឧទ្ធរណ៍នេះ ទាក់ទងនឹងផលវិបាកនៃដីកាដំណោះស្រាយផ្ទុយគ្នា ដែល "ជាប្រធានបទដែលបានដោះស្រាយរួចហើយដោយ ស.ច.ស.អ. នៅក្នុងដីកាសម្រេចចោទប្រកាន់"[31]។ ការនេះធ្វើឱ្យមានភាពស្រពិចស្រពិលទៅលើបញ្ហាគន្លឹះសំខាន់ដែលប្តឹង អ.ប.ជ. ឱ្យដោះស្រាយ។ បើទោះបីជាការបកស្រាយរបស់ ស.ច.ស.អ. ទៅលើវិធាន ៧៧(១៣) ជា *ទស្សនៈមិនសំខាន់* (obiter) ក៏ដោយ ក៏តាមរយៈការលើកឡើងថា ដីកាដំណោះស្រាយទាំងពីរ ឬ មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ នឹងត្រូវតម្កល់ ដោយមិនគិតអំពីសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ ស.ច.ស.អ. បានបញ្ជាក់ *ដោយប្រយោល* រួចទៅហើយទៅលើយុត្តាធិការរបស់ អ.វ.ត.ក. លើលោក មាស មុត។ អ.ប.ជ. ធ្លាប់បានសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដែលបញ្ជាក់ *ដោយប្រយោល* ពីយុត្តាធិការរបស់ អ.វ.ត.ក. តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[32]។

១២. ស.ព.អ. បាននាំឱ្យ អ.ប.ជ. យល់ខុស ដោយបំភ្លៃទឡ្ហីករណ៍របស់លោក មាស មុត ថា បណ្តឹងឧទ្ធរណ៍របស់គាត់ ក៏អាចទទួលយកបាន *ផងដែរ* តាមការបកស្រាយទូលាយ លើសិទ្ធិប្តឹងឧទ្ធរណ៍តាមវិធាន ៧៤(៣)(ក) ដោយផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[33]។ ដោយអះអាងថា "មិនចាំបាច់មានជំនួយលើការបកស្រាយវិធាន ២១" ព្រោះថា "គ្មានអ្វីគួរឱ្យសង្ស័យទេថា" បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនអាចទទួលយកបានតាមវិធាន ៧៤(៣)(ក)[34] ស.ព.អ. គេចវេសពីការពោលប្រាស្រ័យអំពីកាលៈទេសៈពិសេស ដែលតម្រូវឱ្យមានការបកស្រាយទូលាយ លើសិទ្ធិប្តឹងឧទ្ធរណ៍របស់លោក មាស មុត[35] គឺថាដំណោះស្រាយដែលស្នើឡើង ដោយ ស.ច.ស.អ. សម្រាប់ដីកាដំណោះស្រាយដែលផ្ទុយគ្នា គឺមិនមានការគាំទ្រដោយវិធានផ្ទៃក្នុង[36] បណ្តឹងឧទ្ធរណ៍របស់លោក

---

[31] កថាខណ្ឌ ៨ នៃចម្លើយតបរបស់ ស.ព.អ.។

[32] *សូមមើល រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ២៤-២៥។

[33] កថាខណ្ឌ ៨ នៃចម្លើយតបរបស់ ស.ព.អ.។ កថាខណ្ឌ ៣-៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[34] កថាខណ្ឌ ៨ នៃចម្លើយតបរបស់ ស.ព.អ.។

[35] *សូមមើល* កថាខណ្ឌ ៣-៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[36] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ

មាស មុត លើកឡើងពីបញ្ហាដែលមិនអាចកែតម្រូវបានដោយអង្គជំនុំជម្រះសាលាដំបូង[37] និង ការមិនអនុញ្ញាតឱ្យលោក មាស មុត ប្តឹងឧទ្ធរណ៍ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នឹងបង្កព្យសនកម្មដែលមិនអាចកែតម្រូវបាន និង ដកហូតជាអចិន្ត្រៃយ៍ពីលោក មាស មុត នូវសិទ្ធិដែលត្រូវទទួលបានតាមរយៈរដ្ឋធម្មនុញ្ញ គឺសច្ចធារណ៍និរទោស សិទ្ធិការពារក្តី សិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់ ដែលឈានដល់ការសន្និដ្ឋានបញ្ចប់ក្នុងពេលវេលាសមស្របមួយ សិទ្ធិទទួលបានការការពារស្មើគ្នានៅចំពោះមុខ អ.វ.ត.ក. និង សិទ្ធិទទួលបានប្រយោជន៍ពីវិមតិសង្ស័យ[38]។

---

២០១៦ ឯកសារ D120/3/1/8 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២៤។ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D239/1/8 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ១៧។

[37] *សូមមើល រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

[38] *សូមមើល* មាត្រា ៣១, មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលបានវិសោធនកម្មដោយព្រះរាជក្រមចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាទាំងឡាយនៃជំពូកទី៨ ដល់ ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩ ("រដ្ឋធម្មនុញ្ញកម្ពុជា")។ មាត្រា ១២(២), មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។ មាត្រា ៣៣ ថ្មី, មាត្រា ៣៥ ថ្មី (ខ)-(ង) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។ វិធាន ២១(១), វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(១)(២)(៣) (ខ)-(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ៩៩៩ U.N.T.S. ១៧១ ("កតិកាសញ្ញា ICCPR")។ *សូមមើល ផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២៤។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

១៣. ***ផលប្រយោជន៍យុត្តិធម៌ និង ភាពត្រឹមត្រូវនៃនីតិវិធី គាំទ្រដល់ការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត*** អ.ប.ជ. បានទទួលបណ្តឹងឧទ្ធរណ៍ខ្វែងគ្នាពីលោក មាស មុត[39] ស.ព.អ.[40] និង សហព្រះរាជអាជ្ញាជាតិ[41] ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា ដែលទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ទៅលើលោក មាស មុត។ វាអាចនឹងផ្ទុយនឹងផលប្រយោជន៍យុត្តិធម៌[42] និង ភាពត្រឹមត្រូវនៃនីតិវិធី[43] ប្រសិនបើ អ.ប.ជ. សម្រេចថាបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត មិនអាចទទួលយកបាននោះ។ តាមពិតទៅគឺជារឿងមិនសមហេតុផល បើមិនមែនជាការផ្ទុយនឹងភាពយុត្តិធម៌ ដែលធ្វើការពិចារណាទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ខណៈដែលច្រានចោលបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត ជាពិសេស នៅពេលដែលបណ្តឹងឧទ្ធរណ៍ខ្វែងគ្នា មានការជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមក ដោយលើកឡើងពីបញ្ហាគតិយុត្តិ ដែលជាចំណុចស្នូលនៃអ្វីដែល អ.ប.ជ. ត្រូវបានប្តឹងឱ្យដោះស្រាយ ពោលគឺថា តើដីកាដំណោះស្រាយមួយណាក្នុងចំណោមដីកាដំណោះស្រាយទាំងពីរនេះ គួរតម្កល់ជាបានការ ឬ ថាតើដីកាដំណោះស្រាយទាំងពីរត្រូវតម្កល់ដោយ

---

[39] បណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[40] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.")។

[41] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/3 ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ.")។

[42] អ.ប.ជ. "ធ្លាប់ទទួលយកការដាក់ឯកសារមួយចំនួន បើទោះជាមានភាពមិនប្រក្រតីខាងផ្នែកនីតិវិធីក៏ដោយ ដោយផ្អែកលើមូលដ្ឋានថា ការធ្វើដូច្នេះ គឺដើម្បីផលប្រយោជន៍នៃយុត្តិធម៌"។ *សូមមើល* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី" ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D26/1/3 (មតិយោបល់របស់ចៅក្រម Lahuis និង Downing) កថាខណ្ឌ ៩ ដែលដកស្រង់ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ០១) សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៨។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៣៥, ៣៧, ៣៨ និង ៣៩) សេចក្តីសម្រេចលើសំណើសុំពន្យាពេល និង បន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញាក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ខៀវ សំផន អៀង សារី និង ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ប្រឆាំងនឹងដីកាសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម (JEC) ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០១០ ឯកសារ D97/14/9 កថាខណ្ឌ ៧។

[43] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង៖ "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

គ្មានដំណោះស្រាយជារឿងរហូតឬយ៉ាងណា។ ការច្រានចោលបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត នឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខណ្ឌ អ.វ.ត.ក.[44] ជាពិសេសបំផុតនោះ គឺសិទ្ធិរបស់គាត់ក្នុងការប្តឹងឧទ្ធរណ៍ *ប្រកបដោយប្រសិទ្ធិភាព*[45] ដែលរួមទាំងសិទ្ធិទទួលបានការជំនុំជម្រះ[46]។

១៤. ***សរុបមក*** ស.ព.អ. យល់ស្របយ៉ាងជាក់លាក់ថា បណ្តឹងឧទ្ធរណ៍របស់លោក មាស មុត អាចទទួលយកបាន ហើយមានអង្គសេចក្តី។ ការអះអាងណាមួយដែលថា បណ្តឹងឧទ្ធរណ៍របស់លោក

---

[44] *សូមមើល*ជើងទំព័រ ៣៨ *ខាងលើ*។ សូមមើល *ផងដែរ* កថាខណ្ឌ ៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[45] សិទ្ធិក្នុងការធ្វើប្តឹងឧទ្ធរណ៍ គឺមានន័យថាសិទ្ធិក្នុងការធ្វើប្តឹងឧទ្ធរណ៍ *ប្រកបដោយប្រសិទ្ធភាព*។ *សូមមើល ឧទា. រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស (អបជ៥៨) សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និង ចំនួនទំព័រ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D362/4 កថាខណ្ឌ ១០ (សម្រេចថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កម្ពុជា មិន "មានលទ្ធភាពរៀបចំបណ្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាពរហូតទាល់តែមានការចេញសំណៅជាភាសាខ្មែរនៃដីកាដំណោះស្រាយ") (ការគូសបញ្ជាក់បន្ថែម)។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanišić and Župljanin* សំណុំរឿងលេខ IT-08-91-A ដីកាសម្រេចលើញត្តិរបស់ Mićo Stanišić's និង Stojan Župljanin's Motions ស្នើសុំការកម្រិតកំណត់ផ្សេងៗគ្នា លើពេលវេលា និង ចំនួនពាក្យសម្រាប់ដាក់សារណាបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៣ ទំព័រ ២, ៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Šainović et al.* សំណុំរឿងលេខ IT-05-87-A សេចក្តីសម្រេចលើសំណើរួមសុំបន្ថែមពេលវេលាក្នុងការដាក់សារណាចម្លើយតប ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៤។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានសម្រេចថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់អ្នកដាក់ពាក្យសុំ ត្រូវបានរំលោភបំពាននៅក្នុងកាលៈទេសៈដែលរារាំងពួកគេមិនឱ្យមានលទ្ធភាពប្រើប្រាស់ដោយប្រសិទ្ធភាព នូវសិទ្ធក្នុងការធ្វើប្តឹងឧទ្ធរណ៍របស់ពួកគេ។ *រឿងក្តី Marpa Zeeland B.V និង Metal Welding B. តទល់នឹង The Netherlands* ECtHR ពាក្យបណ្តឹងលេខ ៤៦៣០០/៩៩ ចុះថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ៥១។

[46] *សូមមើល* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ជុំ នៅ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D11/3/4/2 (មតិរបស់ចៅក្រម Chung និង Downing) កថាខណ្ឌ ៦៖ "ការគោរពយ៉ាងម៉ឺងម៉ាត់ដល់គោលការណ៍ជាមូលដ្ឋាន នៃដំណើរការតាមផ្លូវច្បាប់ទាំងនេះ ជាការចាំបាច់ដើម្បីធានាឱ្យមានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី និង រក្សាឱ្យមានការតទល់គ្នាដោយ ... អនុញ្ញាតឱ្យភាគី ឬ អ្នកចូលរួម ក្នុងកិច្ចដំណើរការនីតិវិធី មានឱកាសបានបំភ្លឺ ឬ លក្ខណៈទូទៅជាងនេះ គឺថា ពួកគេបានអនុវត្តសិទ្ធិរបស់ខ្លួន"។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Jelisić* សំណុំរឿងលេខ IT-95-10-A សាលក្រម ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ២៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka et al.* សំណុំរឿងលេខ IT-98-30/1-A ដីកាសម្រេចលើការត្រួតពិនិត្យលើសេចក្តីសម្រេចរបស់អ្នកចុះបញ្ជីក្នុងការដកចេញជំនួយផ្លូវច្បាប់ពី Zoran Žigić ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៣៩។

មាស មុត មិនអាចទទួលយកបាន តាមវិធាន ៧៤(៣)(ក) ទោះបីជាបកស្រាយរួម ឬ ដោយឡែកពី វិធាន ២១ នៃវិធានផ្ទៃក្នុង គួរតែត្រូវបានបដិសេធចោលភ្លាមៗ។

## III. អង្គសេចក្តី

### ក. ការឆ្លើយតបចំពោះការអះអាងរបស់ ស.ព.អ. អំពីស្ថានភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់

១៥. ស.ព.អ. អះអាងដោយខុសឆ្គងថា លោក មាស មុត "ប៉ុនប៉ងជាច្រើនលើកក្នុងការបង្ហាញថា ស.ច.ស.ជ. មិនប្រព្រឹត្តិកំហុស"[47] ក្នុងការសម្រេចថា លោក មាស មុត មិន *ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត* ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដើម្បីផ្តល់យុត្តិកម្ម "ថា ដីកាសម្រេចលើកលែងចោទប្រកាន់ មោឃភាពដីកាសម្រេចចោទប្រកាន់..."[48]។ លោក មាស មុត បានធ្វើលើសពីការប៉ុនប៉ងទៅទៀត។ គាត់បានបង្ហាញឱ្យឃើញយ៉ាងសមហេតុផលអំពីរបៀបដែល ស.ច.ស.ជ. មិនមានកំហុស ឬ មិនបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់គាត់ ក្នុងការសម្រេចថាលោក មាស មុត *មិនស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត* និង អំពីមូលហេតុអ្វីដែលស្របនឹងក្របខណ្ឌ អ.វ.ត.ក. ដីកាសម្រេចលើកលែងចោទប្រកាន់ *មានអានុភាពលើ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១៦. បណ្តឹងឧទ្ធរណ៍[49] និង ចម្លើយ[50] របស់លោក មាស មុត ដែលចាំបាច់ត្រូវពិចារណាជាបន្តបន្ទាប់គ្នា ដើម្បីស្វែងយល់ពីទឡ្ហីករណ៍របស់គាត់ដែលថា ដីកាដំណោះស្រាយដែលទាមទារឱ្យលើកលែងចោទប្រកាន់ មានអានុភាពលើដីកាដំណោះស្រាយដែលទាមទារឱ្យបញ្ជូនរឿងទៅជំនុំជម្រះ តាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដោយបង្ហាញថា ស.ច.ស.ជ. បំពេញភារកិច្ចតាមផ្លូវតុលាការរបស់គាត់ ដោយប្រុងប្រយ័ត្ន ប្រកបដោយក្រមសីលធម៌ និង ភាពស្មោះត្រង់ ដោយគោរពទៅតាមពាក្យពេចន៍ និង អត្ថន័យនៃច្បាប់ ហើយបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ ប្រកបដោយសុភវិនិច្ឆ័យ នៅពេលចេញដីកាសម្រេចលើកលែងចោទប្រកាន់។

---

[47] កថាខណ្ឌ ៩ នៃចម្លើយតបរបស់ ស.ព.អ.។

[48] កថាខណ្ឌ ១៨ នៃចម្លើយតបរបស់ ស.ព.អ.។

[49] កថាខណ្ឌ ១៣-៣១, កថាខណ្ឌ ៤៩-៦៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[50] កថាខណ្ឌ ២១-៩៨ នៃចម្លើយតបរបស់ មាស មុត។

១៧. ដោយរំឭកឡើងអំពីបណ្ដឹងឧទ្ធរណ៍របស់គាត់ ស.ព.អ. អះអាងថា ស.ច.ស.ជ.៖

ក. មិនបានធ្វើការសម្រេចតាមការតម្រូវ ទៅលើអង្គហេតុទាំងអស់ដែល ស.ច.ស. បានទទួល[51] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ៤០ ដល់ ៤៤ នៃចម្លើយរបស់លោក មាស មុត។*

ខ. មានកំហុសផ្លូវច្បាប់ ដោយពឹងផ្អែកតែទៅលើភស្តុតាង ដែលបានដាក់ចូលក្នុងសំណុំរឿង នៅមុនថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[52] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ២១ ដល់៣៩ នៃចម្លើយរបស់លោក មាស មុត។*

គ. មានកំហុសផ្លូវច្បាប់ ដោយមិនបានសម្រេចលើអង្គហេតុ និង អង្គច្បាប់ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និង ចំពោះការទទួលខុសត្រូវរបស់លោក មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងអស់នោះ[53] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ៤៥ ដល់ ៥៤ នៃចម្លើយរបស់លោក មាស មុត។*

ឃ. មានកំហុសអង្គហេតុ និង អង្គច្បាប់ ត្រង់ផ្នែកការប្រើប្រាស់កត្តាបង្ហិតបង្ខំ ការគាបសង្កត់ និង បញ្ជារបស់ថ្នាក់លើ ព្រមទាំងការចូលរួមដោយផ្ទាល់ និង កៀកកិតនឹងឧក្រិដ្ឋកម្ម នៅពេលសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត[54] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ៥៥ ដល់ ៧១ នៃចម្លើយរបស់លោក មាស មុត។*

ង. បានធ្វើការសម្រេចលើអង្គហេតុដោយខុសឆ្គង ដែលមានឥទ្ធិពលជាមូលដ្ឋាន ទៅលើបញ្ហាយុត្តាធិការបុគ្គល[55] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ៧២ ដល់ ៨៨ នៃចម្លើយរបស់លោក មាស មុត។*

ច. មានកំហុសអង្គហេតុ ត្រង់ផ្នែកការប្រព្រឹត្តទៅលើជនរងគ្រោះ[56] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ៨៩ ដល់ ៩២ នៃចម្លើយរបស់លោក មាស មុត។*

ឆ. មានកំហុសអង្គច្បាប់ដោយសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់[57] *ត្រូវបានលើកទឡ្ហីករណ៍ប្រឆាំង នៅក្នុងកថាខណ្ឌ ៩៣ ដល់ ៩៦ នៃចម្លើយរបស់លោក មាស មុត។*

---

[51] កថាខណ្ឌ ១១ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើល ផងដែរ* កថាខណ្ឌ ២១-៣៤ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[52] កថាខណ្ឌ ១២-១៤ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើលផងដែរ* កថាខណ្ឌ ៣៥-៦២ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[53] កថាខណ្ឌ ១៥-១៦ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើលផងដែរ* កថាខណ្ឌ ៦៣-៨២ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[54] កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើល* កថាខណ្ឌ ៨៣-១៣៤ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[55] កថាខណ្ឌ ១៤, កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើល ផងដែរ* កថាខណ្ឌ ១៣៥-១៥៤ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

[56] កថាខណ្ឌ ១៤, កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើល ផងដែរ* កថាខណ្ឌ ១៥៥-១៧០ នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ.។

១៨. ស.ព.អ. មិនបានបង្ហាញថាតើ ដោយឡែក ឬ ជារួម កំហុសដែលគាត់ចោទប្រកាន់ថា ស.ច.ស.ជ. បានប្រព្រឹត្ត គឺជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ដោយរបៀបណា ក្នុងការសម្រេចថាលោក មាស មុត មិនស្ថិតក្នុង *ចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត* ដើម្បីជាអង្គសេចក្តីសម្រេចច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់នោះ។

១៩. ***សរុបមក*** បើមិនមានការសម្រេច ដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ. មិនអាចត្រូវបានទុកចោលឡើយ។ តាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដីកាសម្រេចលើកលែងចោទប្រកាន់ មានអនុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីប្រឆាំងលោក មាស មុត *ចាំបាច់ត្រូវតែ* ច្រានចោល។ សូម្បីតែក្នុងលទ្ធភាពដែលថា អ.ប.ជ. ច្រានចោលដីកាសម្រេចលើកលែងចោទប្រកាន់ ដោយសំឡេងភាគច្រើនលើសលប់ក្តី ក៏ អ.ប.ជ. នៅតែចាំបាច់ត្រូវតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលប់ដែរ ដើម្បីឱ្យរឿងក្តីអាចបន្តទៅដំណាក់កាលជំនុំជម្រះ។

**ខ. ការឆ្លើយតបចំពោះការអះអាងរបស់ ស.ព.អ. អំពីផលវិបាកនៃដីកាដំណោះស្រាយផ្ទុយគ្នា**

**១. ក្របខណ្ឌ អ.វ.ត.ក. មិនបានចែងថា រឿងក្តីត្រូវបន្តទៅដំណាក់កាលជំនុំជម្រះឡើយ នៅពេលដែលមានដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានចេញក្នុងពេលដំណាលគ្នានោះ**

២០. ស.ព.អ. អះអាងដោយខុសឆ្គងថា "ច្បាស់ណាស់ថា ក្រោមបញ្ញត្តិដ៏ច្បាស់លាស់ [ក្របខណ្ឌ អ.វ.ត.ក.] ប្រសិនបើ អ.ប.ជ. ខកខានរកមិនបានសំឡេងភាគច្រើនលើសលប់តាមតម្រូវការសម្រាប់សេចក្តីសម្រេចលើដីកាសម្រេចចោទប្រកាន់នោះទេ សំណុំរឿងនឹងត្រូវបញ្ជូនទៅ អ.ជ.ស.ដ."[58]។ មិនមានភស្តុតាងដែលអាចជឿជាក់បាន អាចផ្ទៀងផ្ទាត់បាន ឬ មិនអាចជំទាស់បានដែលថា ភាគីនៃកិច្ចព្រមព្រៀង និង អ្នកតាក់តែងវិធានផ្ទៃក្នុង មានចេតនាឱ្យរឿងក្តីបន្តនីតិវិធីទៅជំនុំជម្រះឡើយ នៅ

---

[57] កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើល ផងដែរ* កថាខណ្ឌ ១៧១-១៩០ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[58] កថាខណ្ឌ ២០ នៃចម្លើយតបរបស់ ស.ព.អ.។

ពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាពដូចគ្នា ត្រូវបានចេញក្នុងពេលដំណាលគ្នានោះ[59]។

២១. ***អ.ប.ជ. មិនត្រូវបានប្តឹងឱ្យដោះស្រាយករណីខ្វែងយោបល់គ្នារវាង ស.ច.ស. ឡើយ*** ស.ព.អ. នាំ អ.ប.ជ. ទៅរកផ្លូវខុស នៅពេលដែលអះអាងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះណា ដែលមិនអាចដោះស្រាយដោយសំឡេងភាគច្រើនលើសលប់ ត្រូវបញ្ជូនទៅជំនុំជម្រះដោយសារតែ "វាប្រាកដជាគ្មានប្រយោជន៍អ្វីឡើយ ក្នុងការទុកបញ្ហាខ្វែងយោបល់គ្នា [រវាង ស.ច.ស.] ដែលអាចកើតមានឡើងចោលដោយគ្មានដំណោះស្រាយនោះ" "ដោយសារតែគោលបំណងនៃការចរចា និង ដំណោះស្រាយដោយសំឡេងភាគច្រើនលើសលប់ គឺដើម្បីដោះស្រាយស្ថានភាពដែល ស.ច.ស. ... មានមតិយោបល់ផ្ទុយគ្នា..."[60]។ ល្បិចផ្គិនភ្នែករបស់ ស.ព.អ. អាចនឹងធ្វើឱ្យ អ.ប.ជ. ទទួលយកការបកស្រាយថ្មីស្រឡាង និង មិនអាចផ្សះផ្សាបាន នៃក្របខណ្ឌ អ.វ.ត.ក. ក្នុងការចាត់ទុកថាវិធាន ៧២ និង វិធាន ៧៧ មិនអាចញែកដាច់ពីគ្នា និង អាចជំនួសគ្នាបាន។

២២. ផ្ទុយពីការអះអាងរបស់ ស.ព.អ.[61] ចំពោះបញ្ហាថាតើ ស.ច.ស. លើកយកនូវមតិខ្វែងគ្នារបស់ពួកគាត់ ដាក់ជូនទៅ អ.ប.ជ. តាមយន្តការដោះស្រាយវិវាទនៃវិធាន ៧២ នៃវិធានផ្ទៃក្នុង ឬយ៉ាងណា ឬថាតើពួកគាត់ចេញដីកាដំណោះស្រាយផ្ទុយគ្នាឬយ៉ាងណានោះ *គឺ* មានភាពពាក់ព័ន្ធ។ យន្តការដោះស្រាយវិវាទ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ឆ្លុះបញ្ចាំងពីមាត្រា ៧ នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ យន្តការនេះមានតួនាទីខុសគ្នា នៅដំណាក់កាលផ្សេងគ្នានៃកិច្ចដំណើរការនីតិវិធីមុនជំនុំជម្រះ ធៀបទៅនឹងវិធាន ៧៧ នៃវិធានផ្ទៃក្នុង ដែលបញ្ញត្តិអំពីនីតិវិធីបណ្តឹងឧទ្ធរណ៍នៅពេលកិច្ចស៊ើបអង្កេតបានបញ្ចប់ ហើយ ស.ច.ស. ចេញដីកាដំណោះស្រាយ[62]។

២៣. នីតិវិធីតាមយន្តការដោះស្រាយវិវាទ គឺមានចែងយ៉ាងច្បាស់ក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ស.ច.ស. មានឆន្ទានុសិទ្ធិទាំងស្រុង ក្នុងការចុះបញ្ជីករណីខ្វែងយោបល់គ្នាផ្ទៃក្នុង តាមវិធាន៧២(១) នៃវិធានផ្ទៃក្នុង ឬ ស្នើដល់ អ.ប.ជ. ឱ្យដោះស្រាយករណីខ្វែងយោបល់ តាមវិធាន ៧២(២)។ ប្រសិនបើ

---

[59] កថាខណ្ឌ ៣២-៤៨ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៥-២០ នៃចម្លើយតបរបស់ មាស មុត។ *សូមមើល ផងដែរ* កថាខណ្ឌ ៤២-៤៦ *ខាងក្រោម*។

[60] កថាខណ្ឌ ២២ នៃចម្លើយតបរបស់ ស.ព.អ.។

[61] កថាខណ្ឌ ២៣ នៃចម្លើយតបរបស់ ស.ព.អ.។

[62] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង៖ សហចៅក្រមស៊ើបអង្កេត "ត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"។

ស.ច.ស. ជ្រើសរើសបញ្ជូនករណីខ្វែងយោបល់ទៅ អ.ប.ជ. តាមវិធាន ៧២(២) នៃវិធានផ្ទៃក្នុង នោះ ស.ច.ស. ត្រូវដាក់ "ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរ អំពីហេតុការណ៍ និង មូលហេតុ នៃករណីខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល"[63] ដែលបន្ទាប់មកត្រូវ "បញ្ជូនឯកសារទាំងនេះ" ទៅ អ.ប.ជ.[64]។ នៅពេលទទួលបានករណីខ្វែងយោបល់គ្នាហើយ អ.ប.ជ. "ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ" ឧទាហរណ៍ដូចជាសម្រេចថា តើ ស.ច.ស. "មានកំហុសក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់..."[65]។

២៨. ដោយប្រើប្រាស់ឆន្ទានុសិទ្ធិតាមផ្លូវតុលាការ ដែលផ្តល់ឱ្យពួកគាត់តាមរយៈវិធានផ្ទៃក្នុង កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[66] ស.ច.ស. បានជ្រើសរើសការមិនស្នើសុំដល់ អ.ប.ជ. ឱ្យដោះស្រាយការខ្វែងយោបល់របស់ពួកគាត់ ដោយចុះបញ្ជីជាលក្ខណៈផ្ទៃក្នុង នូវករណីខ្វែងយោបល់គ្នា[67] និង ចេញដីកាដំណោះស្រាយផ្ទុយគ្នា[68] ដែលជាការគួរឱ្យកត់សម្គាល់ ស.ព.អ. បាន

---

[63] វិធាន ៧២(២) នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ* មាត្រា ៧(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[64] វិធាន ៧២(២) នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ* មាត្រា ៧(៣) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[65] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥ (ការគូសបញ្ជាក់បន្ថែម) ដែលដកស្រង់មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[66] ដោយខុសពីដីកាសម្រេចរបស់អង្គជំនុំជម្រះ ដែលតម្រូវឱ្យចេញសេចក្តីសម្រេចតែមួយ ដោយរួមបញ្ចូលនូវមតិភាគច្រើន និងមតិភាគតិច ក្នុងករណីដែលមិនអាចរកការសម្រេចជាឯកច្ឆន្ទបាន ក្របខណ្ឌ អ.វ.ត.ក. មិនបានតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយរួមគ្នាតែមួយឡើយ។ វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ចែងថា សហចៅក្រមស៊ើបអង្កេត "ត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និង បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"។ វិធាន ១(២) នៃវិធានផ្ទៃក្នុងចែងថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះ ចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ ក្នុងចំណោមអ្នកទាំងពីរ..."។ *Cf.* មាត្រា ៥(២) នៃកិច្ចព្រមព្រៀង។ មាត្រា ១៤ថ្មី(២) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។ សទ្ទានុក្រមនៃវិធានផ្ទៃក្នុង (កំណត់និយមន័យ អង្គជំនុំជម្រះថាជាអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល)។

[67] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D266 ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ៧។ កថាខណ្ឌ ២៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

យល់ស្របថាស្ថិតក្នុងផ្នែកទទួលខុសត្រូវរបស់ ស.ច.ស. និង មិនមែន *ហួសដែនសមត្ថកិច្ច* របស់ខ្លួនឡើយ[69]។

២៥. ស.ព.អ. មិនអាចស្នើសុំ អ.ប.ជ. ឱ្យដោះស្រាយករណីខ្វែងយោបល់គ្នារបស់ ស.ច.ស. តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ឬ ស្នើសុំ អ.ប.ជ. ឱ្យពិចារណាបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា តាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង ថាជាករណីខ្វែងយោបល់គ្នាដែលមិនមានដំណោះស្រាយ តាមរយៈការអនុវត្តវិធាន ៧២ នៃវិធានផ្ទៃក្នុង ដោយសង្ឃឹមថាសម្រេចបាននូវលទ្ធផលដែលខ្លួនចង់បាន ដែលផ្ទុយទៅវិញលទ្ធផលបែបនេះមិនអាចសម្រេចបានឡើយ អនុលោមតាមក្របខណ្ឌ អ.វ.ត.ក. ពោលគឺការបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ នៅពេលដែល ស.ច.ស. ឯករាជ្យ និង មានសិទ្ធិអំណាចដូចគ្នាពីរនាក់ ចេញដីកាដំណោះស្រាយផ្ទុយគ្នា ដែលមានកម្លាំងអនុវត្តស្មើគ្នា។

២៦. ប្រសិនបើ អ.ប.ជ. ចាត់ទុកដោយខុសឆ្គងថា ដីកាដំណោះស្រាយផ្ទុយគ្នា គឺជាករណីខ្វែងយោបល់ដែលមិនមានដំណោះស្រាយ យន្តការដោះស្រាយវិវាទ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ក៏នៅតែ *មិន* អាចដោះស្រាយ ដីកាដំណោះស្រាយផ្ទុយគ្នាដដែល *លុះត្រាតែ* អ.ប.ជ. អាចទទួលបានសំឡេងភាគច្រើនលើសលប់ *ផងដែរ*។ តាមវិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង "សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្រ មានន័យថា ដីកា ... ដែលធ្វើឡើង ដោយ ស.ច.ស. ណាម្នាក់ ត្រូវមានសុពលភាព ឬ មានន័យថា ដីកា ... ដែលបម្រុងនឹងធ្វើដោយ ស.ច.ស. ម្នាក់ ត្រូវតែយកមកអនុវត្ត"។ ប្រសិនបើ អ.ប.ជ. មិនអាចឈានដល់សំឡេងភាគច្រើនលើសលប់ តាមវិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុងទេនោះ ដីកាដំណោះស្រាយទាំងពីរត្រូវមានសុពលភាព ដែលជាលទ្ធផល ដូចដែលបានលើកជាទឡ្ហីករណ៍នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់លោក មាស មុត[70] គឺជារំលោភបំពានលើសិទ្ធិទទួលបានការជំនុំ

---

[68] *សូមមើល* កថាខណ្ឌ ៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់៖ "សហចៅក្រមស៊ើបអង្កេតទាំងពីរ បានឯកភាពចេញដីកាដំណោះស្រាយនេះ ក្នុងពេលតែមួយ ដើម្បីកាត់បន្ថយនូវភាពស្មុគស្មាញនៃនីតិវិធី ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយពីរមុន និង ក្រោយគ្នា"។

[69] *សូមមើល* កថាខណ្ឌ ១០, កថាខណ្ឌ ៣៧ នៃចម្លើយតបរបស់ ស.ព.អ. (ស.ព.អ. យល់ស្របជាមួយលោក មាស មុត ថា ស.ច.ស. មានសិទ្ធិអំណាចឯករាជ្យដូចគ្នា នៅក្រោមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. គឺឆន្ទានុសិទ្ធិក្នុងការមិនជ្រើសរើស យន្តការដោះស្រាយទំនាស់តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង និង មានឆន្ទានុសិទ្ធិក្នុងការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា)។

[70] កថាខណ្ឌ ៤២-៤៤ នៃបណ្ដឹងឧទ្ធរណ៍របស់ មាស មុត។ *សូមមើល ផងដែរ* សារណារបស់ មាស មុត ស្ដីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់ដល់រឿងក្ដី ០០៣ ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០១៧ ឯកសារ D249/2 កថាខណ្ឌ ២៦-៣១។ ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨ ឯកសារ D256/11 កថាខណ្ឌ ៦៧-៦៩។

ជម្រះដោយយុត្តិធម៌ ជាបញ្ហាដែល ស.ច.ស. បានដឹង និង មានការព្រួយបារម្ភរហូតដល់ស្វះស្វែងរកសារណាអំពីបញ្ហា ថាតើត្រូវផ្អាកកិច្ចស៊ើបសួររបស់ពួកគាត់ ដែរឬយ៉ាងណានោះ[71]។ ការទុកចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនអាចជំទាស់បាន ឱ្យនៅលងបន្លាចជនត្រូវចោទគឺ "ជាការមិនសមស្រប តាមតម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋ"[72]។

២៧. នៅពេលនេះ អ.ប.ជ. បានទទួលបណ្តឹងឧទ្ធរណ៍ខ្វែងគ្នា ជំទាស់ដីកាដំណោះស្រាយផ្ទុយគ្នា តាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង[73] គឺមិនមែនជាករណីខ្វែងយោបល់គ្នារវាង ស.ច.ស. តាមវិធាន ៧២ នៃវិធានផ្ទៃក្នុងនោះទេ ដូច្នេះ តួនាទីរបស់ អ.ប.ជ. គឺត្រូវសម្រេចថាតើ ស.ច.ស. បានប្រើប្រាស់ដោយត្រឹមត្រូវដែរឬយ៉ាងណា នូវឆន្ទានុសិទ្ធិរបស់ពួកគាត់ ក្នុងការឈានដល់ការសម្រេចលើយុត្តាធិការបុគ្គលដែលផ្ទុយគ្នា[74] គឺ *មិនមែន* ដោះស្រាយភាពខុសគ្នារបស់ ស.ច.ស. ដែលមិនអាចសម្របសម្រួលបាននោះទេ[75]។

២៨. សម្រាប់បណ្តឹងឧទ្ធរណ៍តាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង ការសម្រេចលើយុត្តាធិការបុគ្គល តាមឆន្ទានុសិទ្ធិរបស់ ស.ច.ស. អាចត្រូវបានបដិសេធចោល តែក្នុងករណីដែល អ.ប.ជ. រកឃើញ៖ (១) កំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចនោះ គ្មានសុពលភាព (២) កំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ និង/ឬ (៣) ការបំពានលើឆន្ទានុសិទ្ធិរបស់ ស.ច.ស.[76]។ អ.ប.ជ. ក៏ត្រូវសម្រេចផងដែរថា កំហុសឆ្គង ឬ ការរំលោភបំពានណាមួយ គឺជា "កត្តាកំណត់ជាមូលដ្ឋាន"

---

[71] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/០២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ១, កថាខណ្ឌ ៥៤។

[72] សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/០២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ៥៤។

[73] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត។ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ.។

[74] *សូមមើល រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២០-២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[75] *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥។

[76] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ *សូមមើល ផងដែរ* កថាខណ្ឌ ៧-១០ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

នៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.[77] ដូចជា ថាសេចក្ដីសម្រេចរបស់ពួកគាត់ ផ្អែកទៅលើកំហុសឆ្គង ឬ ការរំលោភបំពានដែលបានប្រព្រឹត្តជាដើម[78]។ និយាយម្យ៉ាងទៀតគឺថា កំហុសអង្គច្បាប់ចាំបាច់ត្រូវតែមានលក្ខណៈជាមូលដ្ឋាន និង មានអានុភាព ដែល "ពិតជា" ធ្វើឱ្យការសម្រេចរបស់ ស.ច.ស. គ្មានសុពលភាព[79] ចំណែកកំហុសអង្គហេតុ ចាំបាច់ត្រូវតែសំខាន់ជាមូលដ្ឋានចំពោះ

[77] *រឿងក្ដី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ ដែលដកស្រង់ *រឿងក្ដី យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៥២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទង អំពីហិង្សាផ្លូវភេទនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។ *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៦) សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំ ឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ អោ អាន ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៧ ឯកសារ D343/4 កថាខណ្ឌ ១២។ *រឿងក្ដី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៦៧) សាលដីកាស្ដីពីការពិចារណាឡើងវិញ ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៣៦។ *រឿងក្ដី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៤៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៤។ *រឿងក្ដី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៥២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គលដូចរាយនាម នៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្ដីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៥-១៦។ *សូមមើល ផងដែរ រឿងក្ដី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៦២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ៨។

[78] *រឿងក្ដី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[79] *សូមមើល រឿងក្ដី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៥២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាម នៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្ដីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ២១ ខែកក្កដា

សេចក្តីសន្និដ្ឋាន ដែល "ពិតជា" នាំឱ្យមានភាពអយុត្តិធម៌[80] (ឧទាហរណ៍ "លទ្ធផលដែលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ")[81]។ ដើម្បីបង្កើតបានជាការរំលោភបំពានឆន្ទានុសិទ្ធិ សេចក្តីសម្រេចរបស់ ស.ច.ស. ត្រូវតែ "មានភាពអយុត្តិធម៌ ឬ មិនសមហេតុសមផល" ដើម្បី "បង្ខំឱ្យធ្វើការសន្និដ្ឋានថា [ស.ច.ស.] មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ឱ្យបានប្រយ័ត្នប្រយែង"[82]។ នៅពេលគ្មានកំហុសឆ្គង ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស. ណាមួយទេនោះ អ.ប.ជ. មិនអាចជំនួសទស្សនៈរបស់ ស.ច.ស. ដោយទស្សនៈរបស់ អ.ប.ជ. ផ្ទាល់ឡើយ[83]។

---

ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦៖ "អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនមែនគ្រប់កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុទាំងអស់ អាចនឹងធ្វើឱ្យការអនុវត្តឆន្ទានុសិទ្ធិ គ្មានសុពលភាពដែលជាហេតុនាំឱ្យ ច្រានចោលដីកាសម្រេចឡើយ។ ដើមបណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញថា កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ ពិតជានាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព ឬ នាំឱ្យមានភាពអយុត្តិធម៌"។

[80] *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាម នៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦។ *សូមមើល ផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៩ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[81] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៩ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[82] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[83] *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៥-២៧។ *សូមមើល ផងដែរ រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រម

២៩. ***ស.ព.អ. កំណត់លក្ខណៈក្របខណ្ឌ អ.វ.ត.ក. ខុស*** ស.ព.អ. កំណត់លក្ខណៈក្របខណ្ឌ អ.វ.ត.ក. ខុស ដោយអះអាងថា លុះត្រាតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលប់ តាមវិធាន ៧៧(១៣) បើមិនដូច្នេះទេ លោក មាស មុត ត្រូវតែបញ្ជូនទៅជំនុំជម្រះ[84]។ ចំពោះការមិនឆ្លើយតបចំពោះទឡ្ហីករណ៍របស់លោក មាស មុត ដែលថា វិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង អនុវត្តតែចំពោះបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយរួមគ្នា[85] ស.ព.អ. ជាថ្មីម្តងទៀត បានទទូចសុំ អ.ប.ជ. ឱ្យទទួលយកនូវភាសិតប្រាស់ចាកផ្លូវច្បាប់របស់គាត់ដែលថា *នៅពេលមានវិមតិសង្ស័យ ត្រូវជំនុំជម្រះ*[86]។

៣០. ប្រសិនបើ អ.ប.ជ. មិនអាចឈានដល់សំឡេងភាគច្រើនលើសលប់ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងអំពី "សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រ" ចំនួនពីរ៖ តាមវិធាន ៧៧(១៣)(ក) ដីកាសម្រេចក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ត្រូវតម្កល់ទុកជាបានការ"។ តាមវិធាន ៧៧(១៣)(ខ) ត្រូវប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង "ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់ ស.ច.ស."។ ស.ព.អ. យល់ស្របថា វិធាន ៧៧(១៣(ក) "អាចរួមមានទាំងដីកាសម្រេចលើកលែងចោទប្រកាន់" ប៉ុន្តែគាត់មិនបានផ្តល់ទឡ្ហីករណ៍ណាមួយឡើយ កុំថាឡើយដល់ទៅផ្តល់ឯកសារគាំទ្រការអះអាងដែលថា ការអនុវត្តទាំងវិធាន ៧៧(១៣)(ក) និង (ខ) ចំពោះបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយគ្នា នឹងមិននាំទៅដល់លទ្ធផលដែលមិនសមហេតុផល ដែលធ្វើឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតែលងបន្លាចលោក មាស មុត ជានិរន្តរ៍[87]។ ជាក់ស្តែង ស.ព.អ. បានទទួលស្គាល់ទឡ្ហីករណ៍របស់លោក មាស មុត ដែលថា ការអនុវត្តវិធាន ៧៧(១៣)(ក) និង (ខ) នៃវិធានផ្ទៃក្នុង ទៅលើដីកាដំណោះស្រាយផ្ទុយគ្នា នឹងបង្កព្យសនកម្មដែលមិនអាចកែតម្រូវបាន និង ដកហូតដោយអចិន្ត្រៃយ៍ពីលោក មាស មុត នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[88]។

---

ស៊ើបអង្កេត អំពីការណែនាំឱ្យពិចារណាឡើងវិញ លើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៥៖ "អង្គបុរេជំនុំជម្រះបានលើកឡើងដដែលៗថា "អង្គបុរេជំនុំជម្រះមិនអាច យកការយល់ឃើញរបស់ខ្លួន ទៅដាក់ជំនួសការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតបានទេ""។

[84] កថាខណ្ឌ ២៤ នៃចម្លើយតបរបស់ ស.ព.អ.។

[85] កថាខណ្ឌ៤១-៤៨ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[86] កថាខណ្ឌ ២០, កថាខណ្ឌ ២២ នៃចម្លើយតបរបស់ ស.ព.អ.។ កថាខណ្ឌ ១៩១-១៩៨ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។ *សូមមើល ផងដែរ* កថាខណ្ឌ ៤១-៤៨ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៥-២០ នៃចម្លើយតបរបស់ មាស មុត។

[87] កថាខណ្ឌ ២៤ នៃចម្លើយតបរបស់ ស.ព.អ.។

[88] កថាខណ្ឌ ៤១-៤៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

៣១. ស.ព.អ. បានរៀបរាប់អំពីបណ្តឹងឧទ្ធរណ៍របស់គាត់[89] ដោយអះអាងថា វិធាន ៧៧(១៣)(ខ) ជា *ច្បាប់ពិសេស* "មានអានុភាពលើ" បទប្បញ្ញត្តិទូទៅនៃវិធាន ៧៧(១៣)(ក) [90]។ បើដូច្នេះមែន តើយ៉ាងម៉េច។ បើទោះបីជាវិធាន ៧៧(១៣)(ខ) ជា *ច្បាប់ពិសេសទាក់ទង* ជាមួយវិធាន ៧៧(១៣)(ក) ដោយសារតែពាក្យពេចន៍វិធាននោះ ផ្តោតជាក់លាក់ជាងទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏វិធាន ៧៧(១៣)(ខ) នេះ គឺពាក់ព័ន្ធ និង អាចអនុវត្តបាន តែក្នុងករណីដែលមានដីកាដំណោះស្រាយរួមប៉ុណ្ណោះ[91]។ ការអនុវត្តវិធាន ៧៧(១៣)(ខ) ទៅលើបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយគ្នា ដើម្បីឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានអនុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ គឺជារឿងមិនសមហេតុផល និង គ្មានធម្មនុញ្ញភាពទាល់តែសោះ[92]។

៣២. ការបកស្រាយបែបប្រឌិតបោកប្រាស់របស់ ស.ព.អ. ទៅលើវិធានផ្ទៃក្នុង បានធ្វើឱ្យ ស.ច.ស.ជ. មានឋានៈទាបជាងដៃគូរអន្តរជាតិរបស់គាត់ ដែលមានឋានៈស្មើគ្នា[93]។ ការបកស្រាយនេះធ្វើឱ្យ ស.ច.ស.ជ. បាត់បង់សិទ្ធិអំណាចឆន្ទានុសិទ្ធិរបស់គាត់ ក្នុងការបង្ហាញ ក្នុងករណីនេះ ការសម្រេចលើអង្គហេតុ និង ការសម្រេចលើយុត្តាធិការបុគ្គល ដោយឯករាជ្យរបស់គាត់[94]។ ការនេះក៏លុបបំបាត់ដោយអធម្មនុញ្ញភាព នូវគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ចេញពីកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. ដែរ ប្រសិនបើមិនមានដីកាដំណោះស្រាយ ដែលមានអានុភាពស្មើគ្នាណាមួយ ត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលប់ វិមតិសង្ស័យត្រូវដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត[95]។ នៅពេលតាក់តែង និង អនុម័តវិធានផ្ទៃក្នុងចៅក្រម អ.វ.ត.ក. មិនអាចបន្ថយ បន្ទាប ឬ មិនពិចារណាអំពីគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ជាគោលការណ៍ដែលបានធានាដោយរដ្ឋធម្មនុញ្ញ ដូចគ្នាដែរ ភាគីនៃ

[89] កថាខណ្ឌ ១៩៤ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

[90] កថាខណ្ឌ ២៥ នៃចម្លើយតបរបស់ ស.ព.អ.។

[91] កថាខណ្ឌ ៤១, កថាខណ្ឌ ៤៥-៤៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ មាស មុត។

[92] កថាខណ្ឌ ៤១, កថាខណ្ឌ ៤៥-៤៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ មាស មុត។ *សូមមើល ផងដែរ* កថាខណ្ឌ ៣២ *ខាងក្រោម*។

[93] មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[94] *សូមមើល* កថាខណ្ឌ ៤៥ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ *សូមមើល ផងដែរ* ជើងទំព័រ ៦៦ *ខាងលើ*។

[95] *សូមមើល* កថាខណ្ឌ ៤៦, កថាខណ្ឌ ៤៩-៥១ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

កិច្ចព្រមព្រៀង មិនអាចចរចាឱ្យប្រាសចាកពីគោលការណ៍នេះ នៅពេលបង្កើតកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បានឡើយ[96]។

៣៣. ដូចដែល ស.ព.អ. អះអាង ប្រសិនបើវិធាន ៧៧(១៣(ខ) បញ្ជាក់ "យ៉ាងច្បាស់" ថា លោក មាស មុត ត្រូវតែបញ្ជូនទៅជំនុំជម្រះ នៅពេល អ.ប.ជ. មិនអាចរកសំឡេងភាគច្រើនលើសលប់បាន ដើម្បីច្រានចោលដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះមែននោះ[97] ស.ច.ស. *ប្រាកដជាមិនពិចារណា រួមគ្នាថា* "វិធានផ្ទៃក្នុង ៧៧(១៣) គ្រាន់តែចែងអំពីសេណារីយ៉ូ ដែលមានដីកាសម្រេចលើកលែង ចោទប្រកាន់ ឬ ក៏មានដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នានោះទេ" ហើយនៅពេលដែលមិនអាចមានសំឡេងភាគច្រើនលើសលប់ ដើម្បី តម្កល់ដីកាដំណោះស្រាយណាមួយ ក្នុងចំណោមដីកាដំណោះស្រាយទាំងពីរនោះ "ដីកាដំណោះ ស្រាយទាំងពីរត្រូវតម្កល់ទុកជាបានការ តាមការអនុវត្តវិធានផ្ទៃក្នុង ៧៧(១៣)..."[98]។ ស.ច.ស. ទាំងពីរ គឺជាសមាជិកកិច្ចប្រជុំពេញអង្គ មានសិទ្ធិបោះឆ្នោតលើវិធានទាក់ទងនឹងនីតិវិធីរបស់ អ.វ.ត.ក.[99] ដូច្នេះ អាចដឹងច្បាស់អំពីនីតិវិធីអនុវត្តជាធរមានចំពោះដីកាដំណោះស្រាយរបស់ខ្លួន។ ស.ព.អ. មិនតវ៉ាការយល់ឃើញរួមគ្នារបស់ ស.ច.ស. នោះទេ ហើយក៏មិនបានបង្ហាញទឡ្ហីករណ៍ គួរឱ្យជឿជាក់ណាមួយថា វិធាន ៧៧(១៣) អនុវត្តចំពោះបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយផ្ទុយ គ្នានោះដែរ។

៣៤. ស.ព.អ. អះអាងដោយមិនគួរឱ្យជឿជាក់បានថា វិធាន ៧៧(១៣)(ខ) "បង្ហាញអំពីចេតនាក្នុងការ អនុវត្តអាណត្តិយ៉ាងច្បាស់លាស់នៃ [កិច្ចព្រមព្រៀង អ.វ.ត.ក. និង ច្បាប់ អ.វ.ត.ក.]" ដែលថា ក្នុង ករណី ស.ច.ស. ខ្វែងយោបល់គ្នា រឿងក្តី "ត្រូវបន្តទៅដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី" នៅពេល អ.ប.ជ. មិនអាចរកសំឡេងភាគច្រើនលើសលប់បាន[100]។ គ្មានបទប្បញ្ញត្តិណាមួយនៅក្នុង ក្របខណ្ឌ អ.វ.ត.ក. ចែងថា រឿងក្តី "ត្រូវបន្តទៅដំណាក់កាលបន្ទាប់" នៅក្នុងករណីមានការខ្វែង

---

[96] *សូមមើល* កថាខណ្ឌ ៤៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ មាស មុត។

[97] កថាខណ្ឌ ២៥ នៃចម្លើយតបរបស់ ស.ព.អ.។

[98] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥-១៦។

[99] វិធាន ៣, វិធាន ១៨(៣)(ខ) នៃវិធានផ្ទៃក្នុង។

[100] កថាខណ្ឌ ២៥ នៃចម្លើយតបរបស់ ស.ព.អ.។

យោបល់គ្នានោះឡើយ[101]។ ផ្ទុយមកវិញ នៅពេល ស.ច.ស. ខ្វែងយោបល់គ្នា "*ការស៊ើបអង្កេត* ត្រូវបន្តទៅមុខ"[102]។ ដោយបានអនុវត្តឆន្ទានុសិទ្ធិ ចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុផ្ទៃក្នុង[103] ស.ច.ស. បានអនុញ្ញាតឱ្យបន្តការស៊ើបអង្កេត ដោយបានឯកភាពរួមគ្នាចេញដីកាដំណោះស្រាយផ្ទុយគ្នា ក្នុងពេលដំណាលគ្នា[104]។ ស.ច.ស. ទាំងពីរមិនបានធ្វើឱ្យដំណើរការនៃកិច្ចដំណើរការនីតិវិធីជាប់គាំងឡើយ។

៣៥. ជាថ្មីម្តងទៀត ស.ព.អ. ច្របាច់បញ្ចូលយន្តការដោះស្រាយវិវាទ ជាមួយនឹងនីតិវិធីបណ្តឹងឧទ្ធរណ៍ ដោយអះអាងថា ភាគីនៃកិច្ចព្រមព្រៀងមានចេតនាចង់ឱ្យរឿងក្តីដំណើរការទៅជំនុំជម្រះក្នុងសវនាការ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចេញក្នុងពេលដំណាលគ្នា ដោយហេតុថា មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង "ចែងអំពីគោលការណ៍ណែនាំយ៉ាងច្បាស់ពាក់ព័ន្ធនឹងបញ្ហាថាតើត្រូវធ្វើយ៉ាងដូចម្តេច ប្រសិនបើ អ.ប.ជ. មិនអាចដោះស្រាយករណីខ្វែងយោបល់គ្នារវាង ស.ច.ស...."[105]។ ស.ព.អ. បរាជ័យក្នុងការប៉ុនប៉ងលាក់បាំង ការទទួលស្គាល់របស់ខ្លួនថា មាត្រា ៧(៤) "ទាក់ទងនឹងយន្តការដោះស្រាយវិវាទផ្លូវការ... មិនបញ្ជាក់ពីស្ថានភាពច្បាស់លាស់នៅក្នុងករណីបច្ចុប្បន្ននេះទេ"[106] ដែលគាំទ្រជាក់លាក់ដល់ទឡ្ហីករណ៍របស់លោក មាស មុត ដែលថា យន្តការដោះស្រាយវិវាទ និង នីតិវិធីបណ្តឹងឧទ្ធរណ៍ ត្រូវបានចែងកំណត់ដាច់ដោយឡែកពីគ្នា[107]។

---

[101] *ផ្ទុយពី* កថាខណ្ឌ ២៥ នៃចម្លើយតបរបស់ ស.ព.អ.។

[102] *សូមមើល* មាត្រា ៥(៤), ៧(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. (ការគូសបញ្ជាក់បន្ថែម)។

[103] កថាខណ្ឌ ៧ នៃដីកាសម្រេចលើកលែងការចោទប្រកាន់។ កថាខណ្ឌ ២៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិធាន ៧២(១) នៃវិធានផ្ទៃក្នុង។

[104] កថាខណ្ឌ ៦ នៃដីកាសម្រេចលើកលែងការចោទប្រកាន់។ កថាខណ្ឌ ១៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥។

[105] កថាខណ្ឌ ២៦ នៃចម្លើយតបរបស់ ស.ព.អ.។

[106] កថាខណ្ឌ ២៦ ជើងទំព័រ ៩២ នៃចម្លើយតបរបស់ ស.ព.អ.។

[107] *សូមមើល* កថាខណ្ឌ ៣៣-៤០ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៥-២០ នៃចម្លើយតបរបស់ មាស មុត។ *សូមមើលផងដែរ* កថាខណ្ឌ ២១-២៨ *ខាងលើ*។

៣៦. ស.ព.អ. អះអាងដោយមិនសមហេតុផលថា កិច្ចព្រមព្រៀងផ្ទុះបញ្ចាំង "អំពីគោលការណ៍យ៉ាងច្បាស់ក្នុងការធ្វើសេចក្ដីសម្រេចដែលថា ក្នុងករណីដែលមានការខ្វែងយោបល់គ្នា កិច្ចដំណើរការនីតិវិធី គួរតែបញ្ឈប់បាន តាមរយៈសំឡេងភាគច្រើនលើសលប់របស់ចៅក្រម អ.ប.ជ. *តែប៉ុណ្ណោះ*"[108] ដោយសារមានគោលបំណង "ដើម្បីកាត់សេចក្ដី" មេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត[109]។ ភាគីនៃកិច្ចព្រមព្រៀង មិនបានព្រមព្រៀងគ្នាលើ "គោលនយោបាយ" បញ្ជូនរឿងក្ដីទៅជំនុំជម្រះនៅពេល ស.ច.ស. ឈានដល់ការសម្រេចផ្ទុយគ្នា ដែលបង្ហាញអំពីវិមតិសង្ស័យថាតើជនត្រូវចោទស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឬយ៉ាងណានោះទេ។

៣៧. បើគិតពីការដែលថា ភាគីនៃកិច្ចព្រមព្រៀង "យល់ថា ខ្លួនកំពុងកំណត់ 'ការចោទប្រកាន់' ទាំងមូលទៅលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម"[110] បានន័យថា តាមលក្ខណៈជាក់ស្ដែង ប្រសិនបើខ្លួនមានចេតនាផ្ដល់អាទិភាពដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើដីកាសម្រេចលើកលែងចោទប្រកាន់ នៅពេល ស.ច.ស. ឈានទៅការសម្រេចមិនអាចព្រមព្រៀងគ្នាលើយុត្តាធិការបុគ្គល ដែលនាំឱ្យមានការចេញដីកាដំណោះស្រាយផ្ទុយគ្នា ភាគីនៃកិច្ចព្រមព្រៀងប្រាកដជានឹងប្រើប្រាស់ពាក្យជាក់លាក់ថា "រឿងក្ដីត្រូវបន្តទៅមុខ" អនុលោមតាមវិធានស្ដីពីសំឡេងភាគច្រើនលើសលប់ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. បាត់ទៅហើយ[111]។ ភាគីនៃកិច្ចព្រមព្រៀងមិនបានធ្វើដូច្នេះឡើយ។ ហើយ អ.ប.ជ. មិនអាចអានវិធានផ្ទៃក្នុងឱ្យចេញពាក្យពេចន៍ដែលមិនមានរូបរាង ឬ ចេតនាតាមបែបតណ្ហីភាពដែលនាំឱ្យផ្ទុយពីកិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. នោះដែរ។

៣៨. ស.ព.អ. មិនបានបង្ហាញអំពីរបៀបដែល "ស្មារតី និង រចនាសម្ព័ន្ធ" នៃក្របខ័ណ្ឌ អ.វ.ត.ក. ជាមួយនឹងរចនាសម្ព័ន្ធចរចាពិសេស "សហ" បង្ការមិនឱ្យមានភាពនៅក្រោមចំណុះភាគីមួយទៀត[112] ទទួលយកគោលការណ៍ ឬ ចេតនាចង់ឱ្យបន្តកិច្ចដំណើរការនីតិវិធីទៅមុខ នៅពេល ស.ច.ស. ខ្វែង

[108] កថាខណ្ឌ ២៦ នៃចម្លើយតបរបស់ ស.ព.អ. (ការគូសបញ្ជាក់នៅក្នុងឯកសារដើម)។

[109] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ២៧ ដែលដកស្រង់ មាត្រា ១ នៃកិច្ចព្រមព្រៀង (ការគូសបញ្ជាក់នៅក្នុងចម្លើយតបរបស់ ស.ព.អ.)។

[110] កថាខណ្ឌ ២៧ នៃចម្លើយតបរបស់ ស.ព.អ.។

[111] *Cf.* មាត្រា ៥(៤), មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

[112] *សូមមើល* មាត្រា ៦៨ នៃបណ្ដឹងឧទ្ធរណ៍របស់ មាស មុត។

យោបល់គ្នាថា តើជនត្រូវចោទ *ស្ថិតនៅក្នុងចំណោមបុគ្គលទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណា* នោះ[113]។ ក៏គ្មានយុត្តិសាស្ត្រ អ.ប.ជ. ណាមួយគាំទ្រចំណុចនេះដែរ[114]។

៣៩. ស.ច.ស. ម្នាក់ មិនអាចជម្រុញកិច្ចដំណើរការនីតិវិធីទៅមុខដោយឯកឯង តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន នៅពេលដែល ស.ច.ស. ម្នាក់ទៀត ចេញដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងពេលដំណាលគ្នានោះឡើយ[115] ដូចគ្នានេះដែរ អ.ប.ជ. មិនអាចប្រគល់អំណាចដោះស្រាយបណ្តឹងឧទ្ធរណ៍ ឱ្យអង្គជំនុំជម្រះសាលាដំបូង តាមរយៈការបញ្ជូនដីកាដំណោះស្រាយទាំងពីរ ឱ្យអង្គជំនុំជម្រះសាលាដំបូងដោះស្រាយ ក្នុងនាមជាស្ថាប័នថ្នាក់ទី ៣ នៅក្នុងក្របខណ្ឌ អ.វ.ត.ក. នោះដែរ។

៤០. ទោះបីជា វិធាន ៧៩(១) ចែងថា អង្គជំនុំជម្រះសាលាដំបូងទទួល "ដីកាបញ្ជូនរឿងទៅជំនុំជម្រះពី [ស.ច.ស.]" ហើយវិធាន ៦៩(២)(ខ) ចែងថា ប្រសិនបើមានការតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់[116] សំណុំរឿងនោះនឹងត្រូវបានបោះត្រា ហើយរក្សាទុកក្នុងបណ្ណាសារដ្ឋាន វិធានទាំងពីរ មិនខុសពីវិធាន ៧៧(១៣)[117] ត្រូវបានតាក់តែងឡើងសម្រាប់ករណីដីកាដំណោះស្រាយមួយរួមគ្នា មិនមែនសម្រាប់ដីកាដំណោះស្រាយពីរផ្ទុយគ្នានោះទេ។

៤១. ស.ច.ស. ទាំងពីរមានឋានៈស្មើគ្នា[118]។ នៅពេលដែលមិនមានកំហុសឆ្គង ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ. (ដែលក្នុងករណីនេះ គ្មាន)[119]

---

[113] កថាខណ្ឌ ២៨ នៃចម្លើយតបរបស់ ស.ព.អ.។

[114] *សូមមើល* កថាខណ្ឌ ២៨ ជើងទំព័រ ១០២ នៃចម្លើយតបរបស់ ស.ព.អ.។ យុត្តិសាស្ត្រ អ.ប.ជ. ទាំងអស់ដែលបានដកស្រង់ ពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ ស.ច.ស. នៅដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធី មុនពេលចេញដីកាដំណោះស្រាយ។

[115] *ផ្ទុយពី* កថាខណ្ឌ ២៨ នៃចម្លើយតបរបស់ ស.ព.អ.។

[116] ការខកខានរបស់ អ.ប.ជ. មិនបានតម្កល់ដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាទាំងពីរនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ដូចនឹងស្ថានភាពដែលគ្មានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយណាមួយត្រូវបានដាក់ អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង ដែលចែងថា "សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារដ្ឋាន ក្រោយពីផុតរយៈពេលប្តឹងឧទ្ធរណ៍"។

[117] កថាខណ្ឌ ៣២-៤៨ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៥-២០ នៃចម្លើយតបរបស់ មាស មុត។ *សូមមើលផងដែរ* កថាខណ្ឌ ២៩-៣៣ *ខាងលើ*។

[118] មាត្រា ៥(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[119] កថាខណ្ឌ ១៣-៣១, កថាខណ្ឌ ៥២-៦៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ២១-៤៨ នៃចម្លើយតបរបស់ មាស មុត។

ដីកាសម្រេចលើកលែងចោទប្រកាន់ មិនអាចត្រូវបានទុកចោលនោះទេ[120]។ ប្រសិនបើ អ.ប.ជ. ព្យាយាមបញ្ជូនរឿងក្តីទៅជំនុំជម្រះ អ.ប.ជ. ត្រូវបញ្ជូនដីកាដំណោះស្រាយទាំងពីរទៅអង្គជំនុំជម្រះសាលាដំបូង ដែលជាការមិនទំនង ដោយសារថា អង្គជំនុំជម្រះសាលាដំបូង ខុសពី អ.ប.ជ. មិនមានសិទ្ធិអំណាចវិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចរបស់ ស.ច.ស. ឡើយ[121]។

៤២. ***ប្រវត្តិចរចាបញ្ជាក់ថា រឿងក្តីមិនត្រូវបានបញ្ជូនទៅជំនុំជម្រះផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ នៅពេលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចេញក្នុងពេលដំណាលគ្នា*** ស.ព.អ. បង្ហាញប្រវត្តិចរចាមិនត្រឹមត្រូវដោយអះអាងថា វាស្របជាមួយនឹងលទ្ធផលដែល *ខ្លួនគាត់* ចង់បាន[122]។ ស.ព.អ. អះអាងដោយភាន់ច្រឡំថា "លទ្ធភាពនៃការស៊ើបអង្កេត ហើយក្រោយមកទៀតមិនមានការជំនុំជម្រះ ជាដំណោះស្រាយចំពោះការខ្វែងយោបល់គ្នា" ថាតើត្រូវបញ្ជូន ឬ មិនបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ មិនមែនជាអ្វីដែលរាជរដ្ឋាភិបាលកម្ពុជា ("រ.ប.ក.") និង អង្គការសហប្រជាជាតិ ("អ.ស.ប.") មើលឃើញនោះឡើយ[123] តាមរយៈការដកស្រង់សំដីរបស់អ្នកចរចា អ.ស.ប. Hans Corell[124] និង ឯកអគ្គរដ្ឋទូតគោចរណ៍អាមេរិកទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាម David Scheffer[125]។ រ.ប.ក. និង អ.ស.ប. បានមើលឃើញទុកជាមុនថា ស.ច.ស អាចខ្វែងយោបល់គ្នានៅពេលបញ្ចប់កិច្ចស៊ើបសួរ[126] ដោយសារហេតុផលនេះហើយទើបបានផ្តល់អំណាចឆន្ទានុសិទ្ធិដល់ ស.ច.ស. ឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា[127] ហើយឱ្យអ្នកចរចាបង្កើតវិធានស្តីពីសំឡេងភាគច្រើនលើសលប់ សម្រាប់ដំណាក់កាលស៊ើបអង្កេតមុនជំនុំជម្រះ ព្រមទាំងមានបំណងទុកសេណារីយ៉ូដីកាដំណោះស្រាយផ្ទុយគ្នានេះចោល មិនចែងច្បាស់លាស់[128]។

---

[120] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (ការសម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[121] *Cf.* វិធាន ៧៧ នៃវិធានផ្ទៃក្នុង។

[122] កថាខណ្ឌ ២៩-៣២ នៃចម្លើយតបរបស់ ស.ព.អ.។

[123] កថាខណ្ឌ ៣០ នៃចម្លើយតបរបស់ ស.ព.អ.។

[124] កថាខណ្ឌ ៣១ នៃចម្លើយតបរបស់ ស.ព.អ.។

[125] កថាខណ្ឌ ៣២ នៃចម្លើយតបរបស់ ស.ព.អ.។

[126] *សូមមើល* កថាខណ្ឌ ៣៣-៣៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[127] *សូមមើល* កថាខណ្ឌ ៣៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ *សូមមើលផងដែរ* ជើងទំព័រ ៦៦ *ខាងលើ*។

[128] *សូមមើល* កថាខណ្ឌ ៣៣-៣៤ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

៤៣. <u>*Corell*</u>៖ សេចក្តីថ្លែងការណ៍របស់ Corell ក្រោយបញ្ចប់ការចរចាត្រឹមបានបញ្ជាក់ថា នៅពេល ស.ច.ស. ខ្វែងយោបល់គ្នា “ថាតើត្រូវបន្តការស៊ើបអង្កេតឬយ៉ាងណា”[129] គេត្រូវការសំឡេងភាគច្រើនលើសលប់ដើម្បី “បញ្ឈប់ *ការស៊ើបអង្កេត...*”[130]។ លោកមិនបានពន្យល់ស៊ីជម្រៅបន្ថែមនោះទេ ហើយប្រាកដជាមិនបានផ្តល់សុពលភាពដល់ការអះអាងរបស់ ស.ព.អ. ដែលថា ភាគីនៃកិច្ចព្រមព្រៀងមានចេតនាចង់ឱ្យដីកាសម្រេចលើកលែងចោទប្រកាន់ ផ្តល់អាទិភាពដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីឱ្យអាចបញ្ជូនរឿងក្តីទៅជំនុំជម្រះបាននោះឡើយ នៅពេល ស.ច.ស. ចេញដីកាដំណោះស្រាយផ្ទុយគ្នា។ ប្រសិនបើភាគីនៃកិច្ចព្រមព្រៀងមានចេតនាចង់បញ្ជាក់ថា សំឡេងភាគច្រើនលើសលប់ជាលក្ខខណ្ឌរារាំងមិនឱ្យរឿងក្តីបន្តទៅដំណាក់កាលជំនុំជម្រះ នៅពេល ស.ច.ស. ខ្វែងយោបល់គ្នាថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬយ៉ាងណាមែននោះ ដោយសារកណីនេះត្រូវបានយកមកពិភាក្សា[131] ប្រាកដជា Corell បានបញ្ជាក់ពីចំណុចនេះច្បាស់លាស់បាត់ទៅហើយ។ ការដែលមិនមានការបញ្ជាក់លើកឡើងនៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[132] បង្ហាញច្បាស់អំពីការមិនអនុញ្ញាតឱ្យធ្វើដូច្នេះ។

៤៤. <u>*Scheffer*</u>៖ ខណៈដែល Scheffer បានបង្ហាញឱ្យឃើញពីភាពស្ទាក់ស្ទើរក្នុងការលាតត្រដាងឯកសារពាក់ព័ន្ធនឹងប្រវត្តិចរចា[133] ហើយទោះបីជាជំពូកស្តីពីជីវប្រវត្តិរបស់លោក មិនមែនជាឯកសារបញ្ជាក់ករណីនេះក៏ដោយ ក៏ ស.ព.អ. ដកស្រង់អត្ថបទនានាបញ្ជាក់ពីទឡ្ហីករណ៍របស់លោក មាស មុត ដែលថា នៅក្នុងអំឡុងពេលចរចាវិធានស្តីពីសំឡេងភាគច្រើនលើសលប់ដែលនឹងបញ្ជូនរឿងក្តី

---

[129] សេចក្តីថ្លែងការណ៍របស់អគ្គលេខាធិការរង Hans Corell ក្រោយពេលចាកចេញពីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៣ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៣ ឯកសារ D181/2.36 EN 01326112។ *ផ្ទុយពី* កថាខណ្ឌ ៣១ នៃចម្លើយតបរបស់ ស.ព.អ.។

[130] លិខិតពីអគ្គលេខាធិការ អ.ស.ប. Kofi Anna ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០០ ឯកសារ D267.4.1.5 EN 01614369 (ការគូសបញ្ជាក់បន្ថែម)។ *សូមមើលផ្ទុយពី* កថាខណ្ឌ ៣១ នៃចម្លើយតបរបស់ ស.ព.អ.។

[131] *សូមមើល* David Scheffer អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *នៅក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៣១, ២៣៤, ២៤៧ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២០០៨) (ការគូសបញ្ជាក់បន្ថែម) (ឯកសារភ្ជាប់ ១)។ *សូមមើល* កថាខណ្ឌ ៤៥-៤៧ *ខាងក្រោម*។

[132] មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[133] *សូមមើល* កថាខណ្ឌ ១៩ ជើងទំព័រ ៩៣ នៃចម្លើយតបរបស់ មាស មុត។

ទៅជំនុំជម្រះនៅពេល ស.ច.ស ខ្វែងយោបល់គ្នាថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬយ៉ាងណានោះ *ត្រូវបាន* យកមកពិចារណា ប៉ុន្តែ *មិនត្រូវបាន* អនុម័តទទួលយកឡើយ[134]។

៤៥. Scheffer ពន្យល់ថា នីតិវិធីដែលបានពិភាក្សានៅដើមឆ្នាំ ២000 គឺជាសេចក្តីសម្រេច "មិនបន្តការស៊ើបអង្កេត" ឬ "*មិន* បញ្ជូនទៅជំនុំជម្រះ" នឹងត្រូវការសម្រេចដោយសំឡេងភាគច្រើនលើសលប់របស់ចៅក្រម ដើម្បីឱ្យកិច្ចដំណើរការនីតិវិធីបញ្ឈប់បាន[135] ហើយថា នៅពេលមិនមានសំឡេងភាគច្រើនលើសលប់ចំពោះ "សេចក្តីសម្រេចបញ្ជូនទៅជំនុំជម្រះនឹងចាត់ទុកជាបានការ ហើយរឿងក្តីនឹងបន្តទៅជំនុំជម្រះ"[136]។

៤៦. Scheffer លើកឡើងថា នៅចុងខែមេសា ឆ្នាំ ២000 មេធាវី អ.ស.ប. បានព្រមទទួលយកវិធានស្តីពីសំឡេងភាគច្រើនលើសលប់ ទោះបីជា "នៅមានភាពពុំច្បាស់លាស់" លើវិធីប្រើប្រាស់វាក៏ដោយ ពោលគឺ "ត្រូវបញ្ឈប់ ឬ យល់ព្រមឱ្យធ្វើការស៊ើបអង្កេត ឬ បញ្ជូនទៅជំនុំជម្រះ"[137]។ ទោះបីជាយ៉ាងនេះក្តី លោកកត់សម្គាល់ថា នៅឆ្នាំ ២00៣ ការសម្រុះសម្រួលមួយបានលេចឡើង៖ សេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា "បន្តការចោទប្រកាន់នឹងត្រូវទទួលយកលើកលែងតែ [អ.ប.ជ.] បញ្ឈប់ការចោទប្រកាន់នេះដោយសំឡេងភាគច្រើនលើសលប់។ គោលបំណងដូចគ្នាអនុវត្តចំពោះ [ស.ច.ស.] ហើយនឹងចំពោះវិធីដោះស្រាយសេចក្តីសម្រេច និង ការខ្វែងយោបល់គ្នា *លើការស៊ើបអង្កេត* របស់ ស.ច.ស."[138]។ ការយោងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានលុបចេញពីយន្តការដោះស្រាយវិវាទ ដែលត្រូវបានអនុម័តនៅក្នុងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[139]។

---

[134] *សូមមើល* កថាខណ្ឌ ៣៣-៤0 នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[135] David Scheffer អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *នៅក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៣១, ២៣៤, ២៤៧ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២00៨) (ការគូសបញ្ជាក់នៅក្នុងឯកសារដើម) (ឯកសារភ្ជាប់ ១)។

[136] David Scheffer អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *នៅក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៣១, ២៣៤, ២៤៧ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២00៨) (ការគូសបញ្ជាក់នៅក្នុងឯកសារដើម) (ឯកសារភ្ជាប់ ១)។

[137] David Scheffer អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *នៅក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៣១, ២៣៤, ២៤៧ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២00៨) (ការគូសបញ្ជាក់នៅក្នុងឯកសារដើម) (ឯកសារភ្ជាប់ ១)។

[138] David Scheffer អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *នៅក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៣១, ២៣៤, ២៤៧ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២00៨) (ការគូសបញ្ជាក់នៅក្នុងឯកសារដើម) (ឯកសារភ្ជាប់ ១)។

[139] មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង៖ "ការស៊ើបអង្កេត ឬ ការចោទប្រកាន់ត្រូវបន្តដំណើរការទៅមុខទៀត"។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.៖ "ការស៊ើបអង្កេតត្រូវធ្វើបន្ត"។ *សូមមើលផ្ទុយ* David Scheffer អង្គជំនុំជម្រះវិសាមញ្ញក្នុង

៤៧. *យុត្តិសាស្ត្រ អ.វ.ត.ក. មិនគាំទ្រការលើកឡើងថា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" លើសពីដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធីមុនជំនុំជម្រះ* ស.ព.អ. បកស្រាយមិនត្រឹមត្រូវនូវយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ដោយអះអាងថា អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី ០០១ និង អ.ប.ជ. នៅក្នុងរឿងក្តី ០០២ បានសម្រេចថា ពាក្យ "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" មានន័យថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងបន្តដំណើរការទៅជំនុំជម្រះ"[140] ហើយ "រួមបញ្ចូលឃ្លាដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង"[141]។ យុត្តិសាស្ត្រ អ.វ.ត.ក. គ្រាន់តែបញ្ជាក់ថា ពាក្យ "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" មានន័យថា ការខ្វែងយោបល់គ្នារវាង ស.ច.ស. មិនត្រូវនាំឱ្យការស៊ើបអង្កេតជាប់គាំងនោះទេ នៅពេលដែលបានបិទបញ្ចប់ និង ចេញដីកាដំណោះស្រាយ[142]។ នៅពេលចេញដីកាដំណោះស្រាយ ការស៊ើបអង្កេតបានបញ្ចប់ ហើយ ស.ច.ស. លែងមានសមត្ថកិច្ចទៀតហើយ (functus officio)[143]។ អ.ប.ជ. មិនត្រូវបាន "បង្កើតឡើង" ឬ "ផ្តល់សិទ្ធិ" ឱ្យធ្វើការស៊ើបអង្កេតនោះទេ[144]។

៤៨. ក្រៅពីបានចម្លងតាមការបកស្រាយទាំងស្រុងរបស់ខ្លួនលើ *សំអាងហេតុ* របស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី ០០១ ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នាពេលមុនរបស់ខ្លួន[145] ស.ព.អ. មិនមានអ្វីយកមកគាំទ្រការអះអាងរបស់ខ្លួនដែលថា "ការបកស្រាយសមហេតុផលតែមួយគត់" នៃពាក្យ "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" គឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបន្តទៅជំនុំជម្រះ នៅពេលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចេញក្នុងពេលដំណាលគ្នា។

---

តុលាការកម្ពុជា *នៅក្នុង* នីតិព្រហ្មទណ្ឌអន្តរជាតិ ២១៩, ២៣១, ២៣៤, ២៤៧ (M. Cherif Bassiouni 3rd ed. ឆ្នាំ ២០០៨) (ឯកសារភ្ជាប់ ១)។

[140] កថាខណ្ឌ ៣៤ នៃចម្លើយតបរបស់ ស.ព.អ.។

[141] កថាខណ្ឌ ៣៦ នៃចម្លើយតបរបស់ ស.ព.អ.។

[142] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

[143] *សូមមើល* កថាខណ្ឌ ២៩ នៃដីកាបញ្ជូនទៅជំនុំជម្រះ។ *សូមមើលផងដែរ* ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និង សារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ១៨។

[144] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៤។

[145] *សូមមើល* កថាខណ្ឌ ៣៤-៣៥ នៃចម្លើយតបរបស់ ស.ព.អ.។ កថាខណ្ឌ ១៩៥-១៩៦ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.។

ដូចដែលលោក មាស មុត បានពន្យល់នៅក្នុងបណ្ដឹងឧទ្ធរណ៍[146] និង ចម្លើយរបស់ខ្លួន[147] *សំអាងហេតុ* របស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្ដី ០០១ ទាក់ទងនឹងករណីខ្វែងយោបល់គ្នារវាង ស.ច.ស. នៅក្នុងបរិបទនៃយន្តការដោះស្រាយវិវាទ *នៅមុនពេល* ស.ច.ស. ចេញដីកាដំណោះស្រាយ ពោលគឺ នៅពេល "*ស្នើ* ឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់"[148]។

៤៩. ដោយរំឭកអំពីការអះអាងក្លែងក្លាយរបស់គាត់ថា វា "មិនពាក់ព័ន្ធ" នឹងថាតើបញ្ហាចោទ "ស.ច.ស. ណាម្នាក់មានកំហុសនៅក្នុងការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ទៅដល់ អ.ប.ជ. ដោយរបៀបណា ពីព្រោះ "លទ្ធផលចម្បងលើបញ្ហានេះគឺអាចអនុវត្តបានដូចគ្នា" នៅក្រោមយន្តការដោះស្រាយវិវាទ និង នីតិវិធីបណ្ដឹងឧទ្ធរណ៍[149] ស.ព.អ. បកស្រាយយុត្តិសាស្ត្រ អ.ប.ជ. មិនត្រឹមត្រូវ ដោយអះអាងថា ពាក្យ "ការស៊ើបអង្កេតត្រូវបន្ត" រួមបញ្ចូល [] ឃ្លាដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង"[150]។

៥០. អ.ប.ជ. មិនបានសម្រេចថា រឿងក្ដីបន្តទៅជំនុំជម្រះនៅក្នុងករណីមានការខ្វែងយោបល់គ្នា ដែលនាំឱ្យមានដីកាដំណោះស្រាយពីរផ្ទុយគ្នាស្រឡះនោះទេ។ អ.ប.ជ. គ្រាន់តែបានសម្រេចថា នៅពេល ស.ច.ស. ខ្វែងយោបល់គ្នា រួមទាំង ការខ្វែងយោបល់គ្នាទាក់ទងនឹងខ្លឹមសារនៃដីកាដំណោះស្រាយដែល ស.ច.ស. មានចេតនាចង់ចេញ *ការស៊ើបអង្កេត* ត្រូវបន្តទៅមុខ[151]។ បរិបទនេះគឺជាបញ្ហាពាក់ព័ន្ធដែលត្រូវពិចារណា។

---

[146] កថាខណ្ឌ ៣៥-៣៦ នៃបណ្ដឹងឧទ្ធរណ៍របស់ មាស មុត។

[147] កថាខណ្ឌ ១៨ នៃចម្លើយតបរបស់ មាស មុត។

[148] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥ (ការគូសបញ្ជាក់បន្ថែម)។

[149] កថាខណ្ឌ ៣៥ នៃចម្លើយតបរបស់ ស.ព.អ.។ *ទទ្ធីករណ៍ប្រឆាំង* កថាខណ្ឌ ២១-២៨ *ខាងលើ*។

[150] កថាខណ្ឌ ៣៦-២៧ នៃចម្លើយតបរបស់ ស.ព.អ. ដែលដកស្រង់ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៥។

[151] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៤។

៥១. ក្នុងរឿងក្តី ០០២ ស.ច.ស. បានខ្វែងយោបល់គ្នាថា តើជនត្រូវចោទអាចត្រូវជំនុំជម្រះពីបទល្មើសជាតិឬយ៉ាងណា[152]។ ដោយពិចារណាពីកាតព្វកិច្ចក្នុងការចេញដីកាដំណោះស្រាយក្នុងពេលវេលាសមស្រប ស.ច.ស. ទាំងពីរនាក់បានព្រមព្រៀងគ្នាមិនស្នើ អ.ប.ជ. ឱ្យដោះស្រាយការខ្វែងយោបល់របស់ពួកគាត់ ប៉ុន្តែ "ទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចអំពីចំណាត់ការបន្តនៃនីតិវិធីពាក់ព័ន្ធនឹងបទល្មើស[ជាតិ]"[153]។ តាមរយៈការចេញដីកាដំណោះស្រាយរបស់ខ្លួន ជាជាងមិនចាត់វិធានការអ្វីទាំងអស់ ស.ច.ស បានអនុញ្ញាតឱ្យការស៊ើបអង្កេតបន្តទៅមុខ។

៥២. វិធីសាស្ត្ររបស់ ស.ច.ស. ក្នុងរឿងក្តី ០០៣ មានភាពស៊ីសង្វាក់ជាមួយវិធីសាស្ត្រដែលអនុវត្តក្នុងរឿងក្តី ០០២។ ជាជាងធ្វើឱ្យកិច្ចដំណើការនីតិវិធីជាប់គាំងដោយមិនចាត់វិធានការអ្វីសោះ ស.ច.ស. បានអនុញ្ញាតឱ្យការស៊ើបអង្កេតបន្តទៅមុខ៖ ស.ច.ស. បានព្រមព្រៀងគ្នាចុះកំណត់ហេតុខ្វែងយោបល់តាមវិធាន ៧២(១) ជាជាងស្នើ អ.ប.ជ. ឱ្យដោះស្រាយការសម្រេចផ្ទុយគ្នាលើយុត្តាធិការបុគ្គល តាមវិធាន ៧២(២)[154] និង ព្រមព្រៀងគ្នាចេញដីកាដំណោះស្រាយផ្ទុយគ្នានៅពេលដំណាលគ្នា[155]។ កិច្ចស៊ើបអង្កេតបានបន្ត និង បានបញ្ចប់[156]។

៥៣. ដោយមានវិមតិសង្ស័យរួចទៅហើយចំពោះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. លើលោក មាស មុត និង ដោយសារបទដ្ឋានភស្តុតាងនៅពេលជំនុំជម្រះក្តី មានកម្រិតខ្ពស់ជាងបទដ្ឋានសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[157] ការពន្យារកិច្ចនីតិវិធីដោយមិនចាំបាច់ តាមរយៈការបញ្ជូនគាត់ទៅជំនុំជម្រះនោះ គឺមិនត្រឹមតែជាការរំលោភសិទ្ធិរបស់លោក មាស មុត នៅក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី ក្នុង

---

[152] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៥៧៤។

[153] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៥៧៤។

[154] កថាខណ្ឌ ៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ២៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[155] កថាខណ្ឌ ៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់ពី *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៤។

[156] *សូមមើល* វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

[157] *សូមមើល* វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ១៣២៣។

ពេលសមស្របប៉ុណ្ណោះទេ[158] វាថែមទាំងជាការប្រើប្រាស់ពេលវេលា និង ធនធានរបស់ អ.វ.ត.ក. ដោយមិនត្រឹមត្រូវទៀតផង[159]។ ប៉ុន្តែ ដោយមិនសមហេតុផល ស.ព.អ. អះអាងថា "ដំណោះស្រាយដ៏សមហេតុផលបំផុត" ក្នុងការដោះស្រាយដីកាដំណោះស្រាយផ្ទុយគ្នា គឺបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ ដើម្បីអាចឱ្យគាត់ទទួលបានសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌ និង ផលប្រយោជន៍ពីវិធានសំឡេងមតិភាគច្រើនលើសលប់នៅពេលជំនុំជម្រះក្តី[160]។

៥៤. ***សរុបមក*** ស.ព.អ. ជំរុញ អ.ប.ជ. ឱ្យចាត់ទុកដោយមិនត្រឹមត្រូវថា ដីកាដំណោះស្រាយផ្ទុយគ្នា គឺជាការខ្វែងយោបល់គ្នាដែលមិនមានដំណោះស្រាយ ដោយដាក់បញ្ចូលគ្នានូវយន្តការដោះស្រាយវិវាទជាមួយនឹងនីតិវិធីបណ្តឹងឧទ្ធរណ៍ និង កំណត់លក្ខណៈខុសចំពោះប្រវត្តិចរចា និង យុត្តិសាស្ត្ររបស់ អ.វ.ត.ក.។ ភាគីនៃកិច្ចព្រមព្រៀងមិនបានចែង ហើយចៅក្រមដែលព្រាងវិធានផ្ទៃក្នុងក៏មិនបានចែងថា រឿងក្តីមួយបន្តទៅជំនុំជម្រះលើមូលដ្ឋានដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចេញដំណាលគ្នានោះទេ។

### ២. គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* កំណត់ថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៥៥. ជាថ្មីម្តងទៀត ស.ព.អ. នាំ អ.ប.ជ. ទៅរកផ្លូវខុស ដោយអះអាងថា ក្របខណ្ឌ និង យុត្តិសាស្ត្ររបស់ អ.វ.ត.ក. កំណត់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ តែងតែមានអានុភាពលើដីកាសម្រេចលើកលែងចោទប្រកាន់ លើកលែងតែក្នុងករណីដែលដីកាទាំងនេះត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលប់ និង ថា "លទ្ធផលបែបនេះពុំរំលោភគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដោយសារពុំមាន "វិមតិសង្ស័យ" ត្រូវសម្រេចជាប្រយោជន៍នោះទេ ..."[161]។ នៅពេលដែលដីកាដំណោះស្រាយផ្ទុយគ្នាចោទជាបញ្ហាអំពីយុត្តាធិការបុគ្គលលើជនត្រូវចោទក្នុងទម្ងន់ស្មើគ្នា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចមានអានុភាព និង មិនអាចបន្តដំណើរការ

---

[158] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[159] *សូមមើល* ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨ ឯកសារ D256/11 កថាខណ្ឌ ៥១-៥២។

[160] កថាខណ្ឌ ៣៨ នៃចម្លើយតបរបស់ ស.ព.អ.។ *សូមមើលផងដែរ* មាត្រា ៥(១)(ក) នៃកិច្ចព្រមព្រៀង។ មាត្រា ១៤ថ្មី(១)(ក) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[161] កថាខណ្ឌ ៤០ នៃចម្លើយតបរបស់ ស.ព.អ.។

នីតិវិធីទៅដល់ការជំនុំជម្រះឡើយតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*។ ដោយកំណត់លក្ខណៈខុសនូវដំណោះស្រាយនៃដីកាដំណោះស្រាយផ្ទុយគ្នាថាជាបញ្ហានីតិវិធីមិនច្បាស់លាស់ ស.ព.អ. ស្នើដោយឥតអៀនខ្មាស់ឱ្យ អ.ប.ជ. ចៀសវាងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដោយលើកទឡ្ហីករណ៍ថា លោក មាស មុត *ត្រូវតែ* បានជំនុំជម្រះ ដើម្បីជាប្រយោជន៍ក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ដោយមិនគិតពីវិមតិសង្ស័យដែលនាំដល់ការសម្រេចផ្ទុយគ្នារបស់ ស.ច.ស. លើយុត្តាធិការបុគ្គល។

៥៦. ***ដំណោះស្រាយនៃដីកាដំណោះស្រាយផ្ទុយគ្នា មិនមែនជាបញ្ហានៃនីតិវិធីមិនច្បាស់លាស់ទេ ប៉ុន្តែជាវិមតិសង្ស័យ*** ស.ព.អ. នាំ អ.ប.ជ. ទៅរកផ្លូវខុស ដោយអះអាងថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* "ពុំជាប់ពាក់ព័ន្ធនៅក្នុងស្ថានភាពនៃភាពពុំច្បាស់លាស់ផ្នែកនីតិវិធី ដូចករណីនេះឡើយ ករណីថាតើត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះដែរឬទេនោះ"[162]។ អង្គសេចក្តីផ្នែកយុត្តាធិការនៃករណី មាស មុត គឺអត្ថិភាពនៃវិមតិសង្ស័យដែលបានលើកឡើងនៅក្នុងការសម្រេចផ្ទុយគ្នារបស់ ស.ច.ស. លើយុត្តាធិការបុគ្គល មានឥទ្ធិពលលើដំណោះស្រាយនៃដីកាដំណោះស្រាយផ្ទុយគ្នា។ ភាពមិនច្បាស់លាស់ផ្នែកនីតិវិធី មិនមែនជាបញ្ហានៅទីនេះឡើយ។

៥៧. ស.ព.អ. យល់ស្របថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* អនុវត្តដើម្បីដោះស្រាយវិមតិសង្ស័យអង្គហេតុ[163] បញ្ហាអង្គច្បាប់[164] និង មានតួនាទីបន្ទាប់បន្សំ នៅក្នុងការបកស្រាយបទប្បញ្ញត្តិច្បាប់[165]។ ប៉ុន្តែ ដោយភាន់ច្រឡំ ស.ព.អ. បង្កប់ន័យថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* មិនអនុវត្តនៅដំណាក់កាលមុនជំនុំជម្រះឡើយ[166]។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* អនុវត្ត *គ្រប់* ដំណាក់កាល *ទាំងអស់* នៃកិច្ចនីតិវិធី ដែលក្នុងនោះរួមទាំងដំណាក់កាលមុនជំនុំជម្រះផងដែរ[167]។

---

[162] កថាខណ្ឌ ៤១ នៃចម្លើយតបរបស់ ស.ព.អ.។

[163] កថាខណ្ឌ ៤១ នៃចម្លើយតបរបស់ ស.ព.អ.។

[164] កថាខណ្ឌ ៤២ នៃចម្លើយតបរបស់ ស.ព.អ.។

[165] កថាខណ្ឌ ៤៣ នៃចម្លើយតបរបស់ ស.ព.អ.។

[166] *សូមមើល* កថាខណ្ឌ ៤១ នៃចម្លើយតបរបស់ ស.ព.អ.៖ "ដូច មាស មុត ទទួលស្គាល់ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* គឺជាលទ្ធផលនៃសច្ចធារណ៍និរទោស ហើយគឺជាទិដ្ឋភាពនៃលក្ខខណ្ឌតម្រូវថា ពិរុទ្ធភាពត្រូវសម្រេចឱ្យហួសវិមតិសង្ស័យនៅពេលជំនុំជម្រះ"។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៣៨។

[167] *សូមមើល ឧទា. រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ

៥៨. ថាតើ លោក មាស មុត ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឬយ៉ាងណានោះ គឺជាបញ្ហាចម្រុះ ទាំងអង្គហេតុ និង អង្គច្បាប់[168] ដែលតម្រូវឱ្យ ស.ច.ស. អនុវត្តឆន្ទានុសិទ្ធិតុលាការ ឯករាជ្យរបស់ខ្លួន[169]។ ស.ព.អ. យល់ស្របថា ដើម្បីឱ្យ អ.ប.ជ. អាចទុកចោលដីកាដំណោះស្រាយណាមួយបាន អ.ប.ជ. ត្រូវរកសំឡេងភាគច្រើនលើសលប់ ថា ស.ច.ស. ណាម្នាក់បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពាន ដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចថាតើ មាស មុត *ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណា*[170]។ បើគ្មានការសម្រេចដោយសំឡេងភាគច្រើនលើសលប់នោះទេ ការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ និង ការអនុវត្តច្បាប់ ឬ ដីកាដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ មិនមានភាពខ្ពស់ជាង ឬទាបជាង ការស៊ើបអង្កេត ការវាយតម្លៃលើអង្គហេតុ និង ការអនុវត្តច្បាប់ ឬ ដីកា ដំណោះស្រាយរបស់ ស.ច.ស. ម្នាក់ទៀតឡើយ[171]។

---

D427/1/30 កថាខណ្ឌ ៣១០។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៤។ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ពិចារណាថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* អាចយកមកអនុវត្តបាននៅគ្រប់ដំណើរការនៃកិច្ចដំណើរការនីតិវិធី។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Bemba សំណុំរឿងលេខ ICC-01/05-01/08-424 សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ទៅលើបទចោទនានារបស់រដ្ឋអាជ្ញាប្រឆាំង Jean-Pierre Bemba Gombo ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ៣១៖ "ចុងក្រោយ ក្នុងការសម្រេច [ទៅលើការបញ្ជាក់អំពីបទចោទ] អង្គជំនុំជម្រះចង់គូសបញ្ជាក់ថា អង្គជំនុំជម្រះសំអាងលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ជាសមាសធាតុនៃសច្ចាធារណ៍និរទោស ជាគោលការណ៍ទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តដូចគ្នា *ក្រោយមានការកែប្រែជាចាំបាច់* (mutatis mutandis) នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់ រួមទាំងនៅដំណាក់កាលមុនការជំនុំជម្រះលើអង្គសេចក្តីផងដែរ"។

[168] *សូមមើលផងដែរ រឿងក្តី កាំង ហ្កេចអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៣៧៖ "បណ្តឹងសាទុក្ខរបស់ជនជាប់ចោទស្តីពីយុត្តាធិការនេះ ... បានលើកឡើងអំពីបញ្ហារួមគ្នានៃអង្គហេតុ និង អង្គច្បាប់ ..."។

[169] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (សម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២០ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[170] កថាខណ្ឌ ៧ នៃចម្លើយតបរបស់ ស.ព.អ. ។

[171] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨

៥៩. ដោយគ្រាន់តែដោយសារ អ.ប.ជ. មិនយល់ស្របនឹងការសន្និដ្ឋានអង្គហេតុ ឬ ការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. ណាម្នាក់ មិនមានន័យថា អ.ប.ជ. អាចទុកចោលការសម្រេចចិត្តដោយឆន្ទានុសិទ្ធិរបស់ ស.ច.ស. ឡើយ[172]។ អ.ប.ជ. អាចត្រឹមតែបដិសេធការសន្និដ្ឋានអង្គហេតុ នៅពេលរកឃើញថា មិនមាន ស.ច.ស. ដែលមានហេតុផលណាម្នាក់ អាចធ្វើការសន្និដ្ឋានអង្គហេតុបែបនេះ[173]។ អ.ប.ជ. បានបដិសេធមិនជំនួសការយល់ឃើញរបស់ខ្លួន នៅពេលដែលសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ ពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ[174] ពីព្រោះ ស.ច.ស. ធ្វើការវាយតម្លៃរបស់ខ្លួនក្រោយពីមាន "ការយល់ដឹងជ្រៅជ្រះទៅលើសំណុំរឿង"[175]។ ហើយដើម្បីច្រានចោលសេចក្តី

---

ឯកសារ D308/3/1/20 (សម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ *សូមមើលផងដែរ* កថាខណ្ឌ ៦៤, កថាខណ្ឌ ៦៩ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[172] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (សម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២០-២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ *សូមមើលផងដែរ* កថាខណ្ឌ ២៨ *ខាងលើ*។

[173] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៨៦។

[174] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៥-២៦។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ឯកសារ D300/1/7 កថាខណ្ឌ ១៥។

[175] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។

សម្រេចដោយឆន្ទានុសិទ្ធិរបស់ ស.ច.ស. បាន អ.ប.ជ. *ត្រូវ* រកឃើញថាកំហុសអង្គហេតុ “គឺជាកត្តាកំណត់ជាមូលដ្ឋាន” នៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.[176]។ និយាយម្យ៉ាងទៀត កំហុសអង្គហេតុ បើទោះបីជារកឃើញ ត្រូវមានលក្ខណៈសំខាន់ជាកត្តាកំណត់ចំពោះការសន្និដ្ឋានដែលបានធ្វើឡើងដែល “ពិតជា” នាំឱ្យមានភាពអយុត្តិធម៌[177] ពោលគឺ “លទ្ធផលដែលមិនយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ”[178] ។

៦០. ស.ព.អ. យល់ស្របថា គោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនត្រូវចោទ* ដែលចែងក្នុងរដ្ឋធម្មនុញ្ញ និង ក្របខណ្ឌ អ.វ.ត.ក. អនុវត្តដើម្បីដោះស្រាយវិមតិសង្ស័យអង្គហេតុ[179]។ ដោយសារ ស.ច.ស. បានបញ្ជាក់ច្បាស់រួមគ្នា និង បានអនុវត្តកត្តាដូចគ្នា ដើម្បីកំណត់ថាតើ មាស មុត ស្ថិត *ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*[180] និង បានវាយតម្លៃអង្គហេតុដោយផ្អែកលើវិធីសាស្ត្រដូចគ្នា[181] ការសម្រេចផ្ទុយគ្នាលើយុត្តាធិការបុគ្គលដោយ ស.ច.ស. បង្ហាញឱ្យឃើញពី *វិមតិសង្ស័យលើអង្គហេតុ* ដែលត្រូវតែដោះស្រាយដោយអនុវត្តគោលការណ៍ *វិមតិ*

[176] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃ ទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 (សម្រេចជាឯកច្ឆ័ន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[177] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦។ *សូមមើលផងដែរ រឿងក្តី កាំង ហ្គេចអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៩។

[178] *រឿងក្តី កាំង ហ្គេចអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៩ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ *សូមមើលផងដែរ* កថាខណ្ឌ ៧-៩ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[179] កថាខណ្ឌ ៤១ នៃចម្លើយតបរបស់ ស.ព.អ.។

[180] កថាខណ្ឌ ៣៦០-៤០៧ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ៣២-៣៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ *សូមមើលផងដែរ រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ៣-៤១។

[181] កថាខណ្ឌ ៣៥៤-៣៥៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់។ កថាខណ្ឌ ១១៨-១៣១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ *សូមមើលផងដែរ រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ១០៣-១៣៩។

*សង្ស័យត្រូវបានប្រយោជន៍ដល់ជនត្រូវចោទ*។ បើគ្មានការសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ ការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[182] ដែលក្នុងករណីនេះ គ្មាន[183] គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* កំណត់ថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៦១. ***ការច្រានចោលរឿងក្ដី ដោយមូលហេតុគ្មានយុត្តាធិការ មិនរំលោភសិទ្ធិរបស់ជនរងគ្រោះ*** ស.ព.អ. អះអាងដោយនាំឱ្យយល់ខុសថា ដោយហេតុថា វិធាន ២១(១) មិនផ្ដល់ដល់លោក មាស មុត នូវផលប្រយោជន៍ជាស្វ័យប្រវត្តិ នៅក្នុងគ្រប់ស្ថានភាពជាក់ស្ដែងទាំងអស់ ដែលកើតឡើងពីការបកស្រាយវិធានផ្ទៃក្នុង សិទ្ធិរបស់ជនរងគ្រោះត្រូវតែពិចារណា ក្នុងការកំណត់ថាតើត្រូវបញ្ជូនគាត់ទៅជំនុំជម្រះ ឬយ៉ាងណា[184]។ លោក មាស មុត បានអះអាងថា មិនមានការផ្ដល់សិទ្ធិបែបនេះឡើយ។ ស.ព.អ. ក៏បកស្រាយខុសផងដែរនូវយុត្តិសាស្ត្ររបស់ អ.ប.ជ. ដោយរើសយកតែចំណុចណាដែលជាប្រយោជន៍ខ្លួន នៃផ្នែកមួយនៃសេចក្ដីសម្រេចរបស់ អ.ប.ជ. ដែលមិនត្រូវបរិបទ[185]។ អ.ប.ជ. មិនបានសម្រេចថា វិធាន ២១ តម្រូវថា វិធាន *ទាំងអស់* "ត្រូវបកស្រាយក្នុងលក្ខណៈមួយដោយត្រូវពិចារណាអំពីតម្រូវការរបស់សហគមន៍ ដែលរងការប៉ះពាល់..."[186] ឡើយ។ ផ្ទុយទៅវិញ អ.ប.ជ.

---

[182] *រឿងក្ដី អ៊ឹម ចែម* សំណុំរឿងលេខ 00៤/១/0៧-0៩-២00៩-អវតក/កសចស (អបជ ៥0) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២0១៨ ឯកសារ D308/3/1/20 (សម្រេចជាឯកច្ឆន្ទ) កថាខណ្ឌ ២១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[183] *សូមមើល* កថាខណ្ឌ ១៣-៣១, កថាខណ្ឌ ៥២-៦៦ នៃបណ្ដឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ២១-៩៨ នៃចម្លើយតបរបស់ មាស មុត។

[184] កថាខណ្ឌ ៤៤-៤៧ នៃចម្លើយតបរបស់ ស.ព.អ.។

[185] កថាខណ្ឌ ៤៤ នៃចម្លើយតបរបស់ ស.ព.អ. ដែលដកស្រង់ពី *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/កសចស (អបជ 76, អបជ 112, អបជ 113, អបជ 114, អបជ 115, អបជ 142, អបជ 157, អបជ 164, អបជ 165 និង អបជ 172) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់ចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២0១១ ឯកសារ D411/3/6 កថាខណ្ឌ ៦៧។

[186] កថាខណ្ឌ ៤៤ នៃចម្លើយតបរបស់ ស.ព.អ. ដែលដកស្រង់ពី *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/កសចស (អបជ 76, អបជ 112, អបជ 113, អបជ 114, អបជ 115, អបជ 142, អបជ 157, អបជ 164, អបជ 165 និង អបជ 172) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់ចៅក្រមស៊ើប

បានបកស្រាយលក្ខខណ្ឌសម្រាប់ទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណីតាមវិធាន ២៣ ស្ទួន(១)[187] ដោយសម្រេចថា អ.ប.ជ. បកស្រាយវិធានដែលគ្រប់គ្រងការទទួលយកពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី "ដោយគិតពិចារណា... ពីតម្រូវការរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ ..."[188]។ នៅក្នុងសេចក្ដីសម្រេចដដែល អ.ប.ជ. ក៏សម្រេចផងដែរថា សិទ្ធិរបស់ភាគីរដ្ឋប្បវេណីមិនមាន "ឥទ្ធិពលផ្ទាល់ និង ផ្ទុយចំពោះជំហររបស់ជនជាប់ចោទ ដូចជាថាតើត្រូវយកទៅជំនុំជម្រះទោស ឬក៏អត់នោះ..." ទេ[189]។

៦២. ស.ព.អ. បកស្រាយវិធាន ២ ខុស ដោយអះអាងថា វិធាននេះបញ្ជាក់ពីការអះអាងរបស់គាត់ដែលថា សិទ្ធិរបស់ជនរងគ្រោះត្រូវតែបានពិចារណានៅពេលសម្រេចបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ[190]។ វិធាន ២ គ្រប់គ្រងលើនីតិវិធីដែលអនុវត្តចំពោះ *ភាពចន្លោះប្រហោង*។ គ្មាន *ភាពចន្លោះប្រហោង* ឡើយ។ នីតិវិធីដែលគ្រប់គ្រងលើដីកាដំណោះស្រាយផ្ទុយគ្នា គឺច្បាស់លាស់។ ប៉ុន្តែ បើទោះបីជាមាន *ភាពចន្លោះប្រហោង* មែនក៏ដោយ ដូចដែល ស.ព.អ. បានលើកឡើងយ៉ាងត្រឹមត្រូវថា "ក្នុងករណីសេណារីយ៉ូជាក់លាក់មួយពុំលើកឡើងក្នុងវិធានផ្ទៃក្នុងទេនោះ ស្ថាប័នធ្វើសេចក្ដីសម្រេច *ត្រូវ* បកស្រាយបទប្បញ្ញត្តិនេះដោយគោរពច្បាប់កម្ពុជា និង វិធាននីតិវិធីអន្តរជាតិពាក់ព័ន្ធ

អង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៦៧។

[187] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ 76, អបជ 112, អបជ 113, អបជ 114, អបជ 115, អបជ 142, អបជ 157, អបជ 164, អបជ 165 និង អបជ 172) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់ចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៥៦។

[188] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ 76, អបជ 112, អបជ 113, អបជ 114, អបជ 115, អបជ 142, អបជ 157, អបជ 164, អបជ 165 និង អបជ 172) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់ចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៦៧។

[189] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ 76, អបជ 112, អបជ 113, អបជ 114, អបជ 115, អបជ 142, អបជ 157, អបជ 164, អបជ 165 និង អបជ 172) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់ចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៩៧។

[190] កថាខណ្ឌ ៤៥ នៃចម្លើយតបរបស់ ស.ព.អ.។

..."[191]។ ច្បាស់លាស់ណាស់។ ក្នុងការងាកទៅរកច្បាប់កម្ពុជា និង វិធាននីតិវិធីអន្តជាតិ អ.ប.ជ. ត្រូវអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដែលធានាដោយរដ្ឋធម្មនុញ្ញ និង ទទួលយកជាសាកល[192]។

៦៣. ស.ព.អ. អះអាងថា ដោយហេតុថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺជាសិទ្ធិរបស់ភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធី[193] ការច្រានចោលរឿងក្តីប្រឆាំងលោក មាស មុត ដោយគ្មានការរជំនុំជម្រះលើអង្គសេចក្តី អាចនឹងខកខានមិនបានផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ[194]។ ស.ព.អ. នាំ អ.ប.ជ. ទៅរកផ្លូវខុស ដោយមិនគោរពព្រំដែនកំណត់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែលបានចរចា និង ដណ្តើមយកដោយមិនត្រឹមត្រូវនូវអំណាចនីតិបញ្ញត្តិដ៏សម្បើម។ ភាគីនៃកិច្ចព្រមព្រៀងដឹងយ៉ាងច្បាស់ថា នឹងមាន "គម្លាតនិទណ្ឌភាពជាខ្លាំង"[195] និងថា ចារីសក្តានុពលជាច្រើននាក់នឹងមិនត្រូវនាំមកកាត់ទោសឡើយតាមរយៈការដាក់កម្រិតយុត្តាធិការរបស់ អ.វ.ត.ក. ឱ្យនៅត្រឹម "ការនាំយកមកកាត់ទោសនូវមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត..."[196]។ វានឹងមិនមានភាពយុត្តិធម៌ទេ ប្រសិនបើ អ.ប.ជ. កាន់ដោយខុសច្បាប់នូវអំណាចនីតិបញ្ញត្តិ ដោយពង្រីកតាមផ្លូវតុលាការនូវព្រំដែនកម្រិតនៃកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ហើយធ្វើមិនដឹងមិនឮ ឬ កាន់តែអាក្រក់ជាងនេះទៀត បដិសេធការអនុវត្តបទប្បញ្ញត្តិច្បាប់រដ្ឋធម្មនុញ្ញ[197] ជាយុត្តិកម្មសម្រាប់ទទួលបានលទ្ធផលដែលចង់បាន ពោលគឺធ្វើឱ្យត្រូវនូវអ្វីដែលយល់ថាជាការប្រព្រឹត្តខុសរបស់ភាគីនៃកិច្ចព្រមព្រៀង ក្នុងការបង្កើត និង កំណត់កម្រិតយុត្តាធិការរបស់ អ.វ.ត.ក.។

---

[191] កថាខណ្ឌ ៤៥ នៃចម្លើយតបរបស់ ស.ព.អ.(ការគូសបញ្ជាក់បន្ថែមក្នុងឯកសារដើម)។

[192] *សូមមើល*កថាខណ្ឌ ៥០-៥១ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[193] កថាខណ្ឌ ៤៦ នៃចម្លើយតបរបស់ ស.ព.អ.។

[194] កថាខណ្ឌ ៤៧ នៃចម្លើយតបរបស់ ស.ព.អ.។

[195] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ២៥។

[196] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ១៨-១៩។ មាត្រា ១, មាត្រា ២(១) នៃកិច្ចព្រមព្រៀង។ មាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[197] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

៦៤. ស.ព.អ. អះអាងដោយនាំឱ្យយល់ខុសថា គោលបំណងនៃកិច្ចព្រមព្រៀង "*ការស្វែងរកយុត្តិធម៌ និង ការផ្សះផ្សាជាតិ*"[198] តម្រូវឱ្យចៅក្រម និង អង្គជំនុំជម្រះមិនត្រឹមតែស្វែងរកការពិតនូវអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះទៀតផង"[199]។ ដោយមិនបានកាត់បន្ថយជាអប្បរមានូវឥទ្ធិពល និង ការឈឺចាប់របស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលអាចបានកើតឡើង ពួកគាត់មិនអាចចូលរួមប្រកបដោយអត្ថន័យ នៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ ប្រសិនបើ អ.វ.ត.ក. មិនមានយុត្តាធិការលើលោក មាស មុត នោះ។ "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. គឺដើម្បី ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹង *អ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក....*"[200]។ អ.វ.ត.ក. មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដែលហួសពីយុត្តាធិការរបស់ខ្លួន ដើម្បីចៀសវាងការបដិសេធយុត្តិធម៌សម្រាប់ជនរងគ្រោះនោះទេ[201]។ និយាយឱ្យចំ "ការបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានយុត្តាធិការ នឹងធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋាននៃអាណត្តិរបស់ អ.វ.ត.ក. និង ធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងលែងមានអំណាចស្របច្បាប់ដើម្បីជំនុំជម្រះជនជាប់ចោទ"[202]។

៦៥. ស.ព.អ. អះអាងដោយនាំឱ្យយល់ខុសថា ការការពារសិទ្ធិជនត្រូវចោទត្រូវតែបកស្រាយ និង ធ្វើឱ្យមានតុល្យភាពជាមួយនឹងគោលបំណងជាមូលដ្ឋាននៃសាលាក្តីក្នុងការ "នាំមកកាត់សេចក្តី" នូវមេដឹកនាំជាន់ខ្ពស់ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត[203] ពោលគឺធ្វើឱ្យមាន

---

[198] បុព្វកថា នៃកិច្ចព្រមព្រៀង។

[199] កថាខណ្ឌ ៤៨ នៃចម្លើយតបរបស់ ស.ព.អ.។

[200] វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង (ការគូសបញ្ជាក់បន្ថែម)។

[201] *សូមមើល រឿងក្តី កាំង ហ្គេចអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៣៤-៣៧។ Répertoire de droit pénal et de procédure pénale (Dalloz), Frédérique Agostini, Compétence (ខែកុម្ភៈ ឆ្នាំ ២០០៥ ធ្វើបច្ចុប្បន្នភាពនៅខែកុម្ភៈ ឆ្នាំ ២០០៧) កថាខណ្ឌ ២១៣៖ "Comme toute juridiction pénale, le juge d'instruction a le droit mais aussi le devoir, une fois qu'il est saisi, de vérifier sa compétence territoriale, matérielle et personnelle." [ការបកប្រែក្រៅផ្លូវការ៖ "ដូចតុលាការព្រហ្មទណ្ឌនានាដែរ នៅពេលទទួលយកសំណុំរឿងមកពិនិត្យ ចៅក្រមស៊ើបអង្កេតមានសិទ្ធិតែក៏មានភារកិច្ចអនុវត្តន៍យុត្តាធិការដែនដី យុត្តាធិការតាមសាច់រឿង និង យុត្តាធិការបុគ្គល"]។ *សូមមើល* កថាខណ្ឌ ៣១-៣២ នៃចម្លើយតបរបស់ មាស មុត។

[202] *រឿងក្តី កាំង ហ្គេចអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៣៤។

[203] កថាខណ្ឌ ៤៩ នៃចម្លើយតបរបស់ ស.ព.អ.។

តុល្យភាពរវាងសិទ្ធិរបស់ជនត្រូវចោទ "ជាមួយនឹងតម្រូវការក្នុងការបញ្ជាក់ការពិតអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់... ព្រមទាំងជាមួយនឹងគោលការណ៍ទូទៅនៃដំណើរការស្វែងរកយុត្តិធម៌ឱ្យបានសមស្របផងដែរ"[204]។ ជាឧបាយកលបញ្ឆោតមួយទៀត។

៦៦. ស.ព.អ. លើកទឡ្ហីករណ៍យ៉ាងច្បាស់លាស់ថា គ្រប់ជនសង្ស័យដែលត្រូវបានស៊ើបអង្កេត នៅ អ.វ.ត.ក. *ត្រូវតែ* យកមកជំនុំជម្រះទោស ដោយមិនគិតពីវិមតិសង្ស័យថាតើពួកគេស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ឬយ៉ាងណានោះទេ ដែលជាការផ្តល់នូវភាពរំជួលចិត្ត និង វោហាសាស្ត្រគេចវេស ជាជាងការផ្តល់សំអាងគាំទ្រដែលពាក់ព័ន្ធ និង អាចជឿជាក់បាន។ ប្រសិនបើ វ.ប.ក និង អ.ស.ប. មានបំណងចង់ធានាថា គ្មានកម្មាភិបាលខ្មែរក្រហមណាម្នាក់អាចគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ម្ល៉េះសមពួកគេនឹងមិនមានយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. កំណត់ឱ្យនៅត្រឹមមេដឹកនាំជាន់ខ្ពស់ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ[205] ដែល ស.ព.អ. ទទួលស្គាល់ថាផ្ទុះបញ្ចាំងនៅក្នុងគោលបំណងជាមូលដ្ឋាននៃសាលាក្តីនេះ[206]។

៦៧. ស.ព.អ. កំណត់លក្ខណៈខុសលើយុត្តិសាស្ត្ររបស់ អ.ប.ជ. ដោយអះអាងថា ស.ច.ស. និង អ.ប.ជ. មានកាតព្វកិច្ចប្រកាន់ខ្ជាប់នូវ "ភាពចាំបាច់ជារួម ដើម្បីឱ្យការស៊ើបអង្កេត និង ដំណើរការតុលាការបន្តទៅមុខ"[207]។ អ.ប.ជ. បានត្រឹមតែសម្រេចថា ស.ច.ស. និង អ.ប.ជ. ត្រូវតែបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងពេលវេលាសមស្រប អនុលោមតាមវិធាន ២១(៤)[208]។ អ.ប.ជ. មិនបាន

---

[204] កថាខណ្ឌ ៤៩ នៃចម្លើយតបរបស់ ស.ព.អ.។

[205] មាត្រា ១, មាត្រា ២(១) នៃកិច្ចព្រមព្រៀង។ មាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[206] កថាខណ្ឌ ៤៩ នៃចម្លើយតបរបស់ ស.ព.អ.។

[207] កថាខណ្ឌ ៥០ នៃចម្លើយតបរបស់ ស.ព.អ. ដែលដកស្រង់ពី *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D314/1/8 កថាខណ្ឌ ៧០។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ និង សេចក្តីសន្និដ្ឋានបន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា សុំឱ្យស្តាប់ចម្លើយសាក្សីមួយចំនួន (D318, D319, D320, D336, D338, D339 & D340) ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D375/1/8 កថាខណ្ឌ ១០២។

[208] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D314/1/8 កថាខណ្ឌ ៧០។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ និង សេចក្តីសន្និដ្ឋាន

សម្រេច ថ្លែង ឬ បង្កប់ន័យថា ស.ច.ស. និង អ.ប.ជ. មានកាតព្វកិច្ចធ្វើឱ្យទៅមុខនូវដំណើរការតុលាការឱ្យដល់ដំណាក់កាលបន្ទាប់នៃនីតិវិធីឡើយ ជាពិសេសនៅពេលមានវិមតិសង្ស័យថា តើជនត្រូវចោទស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ឬយ៉ាងណានោះ។

៦៨. ស.ព.អ អះអាងដោយនាំឱ្យយល់ខុសថា "ប្រសិនបើភាពមិនប្រាកដប្រជានៃនីតិវិធី អនុញ្ញាតឱ្យផលប្រយោជន៍ដោយស្វ័យប្រវត្តិដល់ជនត្រូវចោទ រហូតអាចបញ្ចប់កិច្ចដំណើរការនីតិវិធីនោះ" ចំណុចនេះនឹងជាការរំលោភច្បាប់នីតិវិធីរបស់កម្ពុជា (ដែលចែងអំពីមូលហេតុនៃការរំលត់បណ្តឹងអាជ្ញា) និង ក្របខណ្ឌ អ.វ.ត.ក. ដោយហេតុថា វិធាន ៦៧(៣) មិនអនុញ្ញាតការលើកលែងចោទប្រកាន់ យោងតាមការពិចារណាលើនីតិវិធីនោះឡើយ[209]។ លោក មាស មុត មិនបានស្នើសុំឱ្យ *ច្រានចោលរឿងក្តីរបស់គាត់* ដោយមូលហេតុអ្វីផ្សេងក្រៅតែពីការគ្មានយុត្តាធិការឡើយ[210] ដែលជាសំណើសុំដំណោះស្រាយដែលផ្តល់ឱ្យដោយក្របខណ្ឌ អ.វ.ត.ក.[211]។

៦៩. វិមតិសង្ស័យលើអង្គហេតុថាតើ លោក មាស មុត *ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត* ឬយ៉ាងណានោះ គឺត្រូវតែដោះស្រាយជាប្រយោជន៍របស់គាត់ ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និង ក្របខណ្ឌ អ.វ.ត.ក.[212]។ ស.ព.អ. មិនបានផ្តល់ការគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា ការច្រានចោលរឿងក្តីរបស់ មាស មុត ដោយសារមូលហេតុមិនមានយុត្តាធិការបុគ្គល គឺជាការជ្រៀតជ្រែកក្នុងរដ្ឋបាលតុលាការ ឬ មិនបានការពារផលប្រយោជន៍របស់គាត់ឡើយ[213]។ ផ្ទុយទៅវិញ ការបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ ដើម្បីឱ្យគាត់អាច "ទទួលប្រយោជន៍" ពីវិធានសំឡេងភាគច្រើនលើសលប់របស់អង្គជំនុំជម្រះសាលាដំបូង ដូចដែល ស.ព.អ. អះអាងដោយមិនសមហេតុផល[214] ពោលគឺ ដើម្បីចំណាយពេលវេលា និង ធនធានលើការជំទាស់បឋម និង អាចទៅជាសវនាការពេញលេញ គឺមិនត្រឹមតែអាចជាការរំលោភសិទ្ធិរបស់លោក មាស

---

បន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា សុំឱ្យស្តាប់ចម្លើយសាក្សីមួយចំនួន (D318, D319, D320, D336, D338, D339 & D340) ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D375/1/8 កថាខណ្ឌ ១០២។

[209] កថាខណ្ឌ ៥០ នៃចម្លើយតបរបស់ ស.ព.អ.។

[210] ទំព័រ ៤៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។

[211] *សូមមើល* វិធាន ៦៧(៣)(ក) នៃវិធានផ្ទៃក្នុង។

[212] កថាខណ្ឌ ៤៩-៦៦ នៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត។ កថាខណ្ឌ ១៧ នៃចម្លើយតបរបស់ មាស មុត។

[213] កថាខណ្ឌ ៤៩-៥០ នៃចម្លើយតបរបស់ ស.ព.អ.។

[214] កថាខណ្ឌ ៣៨, កថាខណ្ឌ ៥០ នៃចម្លើយតបរបស់ ស.ព.អ.។

មុត ក្នុងការទទួលបានការបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងពេលវេលាសមស្របតែប៉ុណ្ណោះទេ[215] ថែមទាំងជាការប្រើប្រាស់ពេលវេលា និង ធនធានរបស់ អ.វ.ត.ក. ដោយមិនល្អាសវៃទៀតផង[216]។

៧០. ***សរុបមក*** ស.ព.អ. ទទូចសុំ អ.ប.ជ ឱ្យធ្វើមិនដឹងមិនឮថា អ.វ.ត.ក. ត្រូវបានបង្កើតឡើងជាតុលាការ "យុត្តិធម៌តាមបែបជម្រើស"[217]។ ទោះជាយ៉ាងនេះក្តី អ.ប.ជ. អាចគិតថាមានចន្លោះប្រហោងនិទណ្ឌភាព ដែលទទួលស្គាល់ដោយភាគីនៃកិច្ចព្រមព្រៀង នៅពេលចរចា និង ពេលបង្កើត អ.វ.ត.ក.[218] ប៉ុន្តែ អ.ប.ជ. មិនត្រូវបានផ្តល់នូវអំណាចឱ្យមិនគោរពព្រំដែនកំណត់យុត្តាធិការដែលគេដាក់ឱ្យ ដើម្បីធានាថាជនរងគ្រោះបានចូលរួមក្នុងតុលាការ ឬ ឱ្យចូលពាក់ព័ន្ធនឹង *ទ្រឹស្តីផលវិបាកនិយម* (Consequentialism) ដោយអានកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង ឱ្យស្របទៅនឹងការបកស្រាយដែលគ្រោងទុក នូវអ្វីដែលបានចរចា ឬ អ្វីដែលគ្រោងទុកជាមធ្យោបាយក្នុងការសម្រេចតាមលទ្ធផលដែលចង់បានឡើយ[219]។

## IV. សន្និដ្ឋាន

៧១. ទោះបីជាមានការអះអាងផ្ទុយរបស់គាត់នាពេលថ្មីៗក៏ដោយ ក៏ ស.ព.អ. ទទួលស្គាល់យ៉ាងច្បាស់នូវភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត ដោយស្នើឱ្យ អ.ប.ជ. ពិចារណាលើការតវ៉ាអំពីយុត្តាធិការរបស់លោក មាស មុត ដោយព្យាយាមធ្វើឱ្យ អ.ប.ជ. ជាប់ពាក់ព័ន្ធនឹង

---

[215] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[216] *សូមមើល* កថាខណ្ឌ ៥១-៥២ នៃចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពរ។

[217] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ៣១។

[218] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 កថាខណ្ឌ ១៨-១៩, កថាខណ្ឌ ២៥។

[219] ដូចដែលសាស្ត្រាចារ្យ Donald L. Drakeman កត់សម្គាល់ថា "ការទទួលយកភាពបត់បែនក្នុងការបកស្រាយរបស់អ្នកសិក្សាស្រាវជ្រាវមួយចំនួន គឺជាផ្នែកនៃការលេចឡើងនូវទស្សនៈរបស់បញ្ញាវ័ន្តជាអន្តរជាតិ ដែលជំរុញឱ្យចៅក្រមដែលចេញសេចក្តីសម្រេចត្រូវសំអាងជាចម្បងទៅលើផលវិបាកនៃសេចក្តីសម្រេចទាំងនោះ ជាជាងទៅលើដំណើរការបកស្រាយតាមបែបប្រពៃណី។ អ្នកសិក្សាស្រាវជ្រាវទាំងនេះមានបំណងជូនដំណឹង និង ប្រហែលជាជំនួស នូវទឡ្ហីករណ៍ជាយូរអង្វែងអំពីរបៀបបកស្រាយអត្ថបទច្បាប់ ដោយផ្តោតលើផលវិបាកទៅលើលទ្ធផលដែលរំពឹងទុកចំពោះសេចក្តីសម្រេចរបស់តុលាការ"។ *សូមមើល* Donald L. Drakeman ផលវិបាកនិយម និង ព្រំដែននៃការបកស្រាយ៖ តើគោលបំណងសមនឹងមធ្យោបាយដែរឬអត់? ៩ យុត្តិសាស្ត្រ ៣០០, ៣០០-៣០១ (Routledge ឆ្នាំ២០១៨) (ឯកសារភ្ជាប់ ២)។

ភាពអយុត្តិធម៌ គឺមិនគោរពទាំងស្រុងនូវរដ្ឋធម្មនុញ្ញកម្ពុជា និង ពាក្យពេចន៍ដែលតាក់តែងដោយប្រុងប្រយ័ត្ននៃក្របខណ្ឌ អ.វ.ត.ក. និង អនុវត្ត "គោលនយោបាយសម្រេចសេចក្តី" ដែលគ្មានរូបរាង ថា រឿងក្តី អ.វ.ត.ក. បន្តកិច្ចដំណើរការនីតិវិធីដល់ជំនុំជម្រះ នៅពេល ស.ច.ស ពីរនាក់មានឋានៈស្មើគ្នាចេញដីកាដំណោះស្រាយផ្ទុយគ្នាស្រឡះដែលមានកម្លាំងអនុវត្តស្មើគ្នា ដោយជំរុញ អ.ប.ជ. ឱ្យ (ក) ប្រែ ក្លាយដំណើរការបណ្តឹងឧទ្ធរណ៍ទៅជាយន្តការដោះស្រាយវិវាទ ដោយចាត់ទុកដីកាដំណោះស្រាយផ្ទុយគ្នាជាការខ្វែងយោបល់ដែលមិនមានដំណោះស្រាយ (ខ) បង្កើតការបកស្រាយច្បាប់វៀចវេដែលអាចដកហូតពី ស.ច.ស.ជ. នូវឋានៈស្មើគ្នា និង សិទ្ធិអំណាចឆន្ទានុសិទ្ធិរបស់គាត់ និង (គ) មិនអើពើដល់គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដោយចាត់ទុកដំណោះស្រាយនៃដីកាដំណោះស្រាយផ្ទុយគ្នា ថាជាភាពមិនច្បាស់លាស់ផ្នែកនីតិវិធី និង (ឃ) បង្កើត *ចន្លោះប្រហោង* ដើម្បីបំពានព្រំដែនកំណត់នៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែលបានចរចា ថា ជាយុត្តិកម្មសម្រាប់ធ្វើឱ្យទៅជាត្រូវនូវអ្វីដែលយល់ថា ជាកំហុសប្រព្រឹត្តដោយភាគីនៃកិច្ចព្រមព្រៀង។

៧២. នៅក្នុងការចរចាក្នុងរយៈពេលមួយទសវត្សរ៍រហូតដល់ការបង្កើតក្របខណ្ឌ អ.វ.ត.ក. ភាគីនៃកិច្ចព្រមព្រៀង និង អ្នកពង្រាងវិធានផ្ទៃក្នុងមិនបានចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពដោយស្វ័យប្រវត្តិលើដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ។ ពួកគេមិនអាចចរចាឱ្យប្រាសចាកពីគោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនត្រូវចោទ* ដែលធានាដោយរដ្ឋធម្មនុញ្ញដូចដែល អ.ប.ជ. មិនអាចមិនគោរពការអនុវត្តគោលការណ៍នេះ នៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. យ៉ាងដូច្នេះដែរ។ ការការពារដោយរដ្ឋធម្មនុញ្ញ និង ព្រំដែនកំណត់យុត្តាធិការបុគ្គលដែលបានចរចា មិនអាចត្រូវបានចៀសវាង ដើម្បីទូទាត់នឹងអត្ថិភាពនៃចន្លោះប្រហោងនិទណ្ឌភាព និង ការប៉ុនប៉ងផ្តល់ឱ្យជនរងគ្រោះនូវភាពយុត្តិធម៌ដែលគួរទទួលបាន ដែលសិទ្ធិដែលពួកគេមិនមាន ផ្អែកលើការអនុវត្តដ៏តឹងរ៉ឹងនៃក្របខណ្ឌ អ.វ.ត.ក.។

៧៣. ស.ច.ស. ទាំងពីរនាក់ មានឋានៈស្មើគ្នា។ ដីកាដំណោះស្រាយរបស់ ស.ច.ស. ទាំងពីរនាក់ មានកម្លាំងអនុវត្តស្មើគ្នា។ *វិមតិសង្ស័យ* ដែលកើតចេញពីការសម្រេចលើអង្គហេតុ និង ការសម្រេចលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. ដែលផ្ទុយគ្នាស្រឡះ ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត អនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*។

៧៤. បណ្ដឹងឧទ្ធរណ៍របស់លោក មាស មុត គឺអាចទទួលយកបាន។ ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ត្រូវតែច្រានចោលរឿងក្ដីប្រឆាំងនឹងលោក មាស មុត។

សូមលោកចៅក្រមមេត្តាទទួលយកការឆ្លើយតបនេះដោយក្ដីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **១៩** ខែ**សីហា** ឆ្នាំ **២០១៩**

សហមេធាវីការពារក្ដីលោក មាស មុត

អាង ឧត្ដម

Michael G. KARNAVAS